# ព្រំដែននៃកម្មវិធីសហគមន៍ដឹកនាំអនាម័យទាំងស្រុង (SLH) ៖ នវានុវត្តន៍ និងចំណេះដឹង




## យន្តការគាំទ្រដើម្បីពង្រឹងសមភាព និងការមិនរើសអើង (EQND) ក្នុងអនាម័យនៅជនបទ (ភាគ ២/២)

**Jeremy Kohlitz, Naomi Carrard** និង **Juliet Willetts,**
សាកលវិទ្យាល័យបច្ចេកវិទ្យាស៊ីដនី – វិទ្យាស្ថានដើម្បីអនាគតប្រកបដោយនិរន្តរភាព

ខែ កញ្ញា ឆ្នាំ ២០២០

The Sanitation Learning Hub at institute of development studies
https: //sanitationlearninghub.org

## អំពី The Sanitation Learning Hub

វិទ្យាស្ថានអភិវឌ្ឍន៍សិក្សា បាននិងកំពុងគាំទ្រដល់កម្មវិធីសហគមន៍ដឹកនាំអនាម័យទាំងស្រុង (SLH) តាំងពីពេលចាប់ផ្តើមដំបូង។ SLH បានក្លាយជាចលនាអន្តរជាតិ ដែលធ្វើឱ្យមានការទទួលស្គាល់ វិទ្យាស្ថានអភិវឌ្ឍន៍សិក្សាជាមជ្ឈមណ្ឌលចំណេះដឹង។

មជ្ឈមណ្ឌលចំណេះដឹង មានគោលបំណងស្វែងយល់ពីតថភាពតាមមូលដ្ឋាន ស្តីពីការអនុវត្ត SLH ក៏ដូចជារៀនសូត្រ ចែករំលែក និងលើកកម្ពស់ការអនុវត្តល្អ គំនិត និងនវានុវត្តន៍ដែលជំរុញឱ្យមាននិរន្តរភាព និងវិសាលភាព។ យើងខិតខំធ្វើយ៉ាងណារក្សាទំនាក់ទំនងជាមួយសហគមន៍ SLH និងផ្តល់ព័ត៌មានត្រឹមត្រូវដល់សហគមន៍ទាំងនោះ ព្រមឱកាសសម្រាប់ការឆ្លុះបញ្ចាំង រៀនសូត្រ និងផ្លាស់ប្តូរចំណេះដឹងជាប់ជាប្រចាំ។ យើងបានសហការជាមួយអ្នកអនុវត្តន៍ អ្នកតាក់តែងគោលនយោបាយ អ្នកស្រាវជ្រាវ និងអ្នកពាក់ព័ន្ធផ្សេងទៀតដែលធ្វើការក្នុងផ្នែកអភិវឌ្ឍន៍ អនាម័យ និងសហគមន៍ពាក់ព័ន្ធ។

គោលដៅរួមនៃ មជ្ឈមណ្ឌលចំណេះដឹង គឺដើម្បីរួមចំណែកពង្រឹងសេចក្តីថ្លៃថ្នូរ សុខភាព និងសុខុមាលភាពរបស់កុមារ ស្ត្រី និងបុរសក្នុងប្រទេសកំពុងអភិវឌ្ឍន៍ ព្រោះពួកគេកំពុងប្រឈមនឹងផលវិបាកនៃការគ្មាន ឬកង្វះអនាម័យ។

គម្របមុខ៖

គ្រួសារក្នុងកម្មវិធី CHOBA ដែលរស់នៅក្នុងខេត្តត្រាវិញ ប្រទេសវៀតណាម, East Meets West។

ក្រេឌីត ៖ MORGAN OMMER

# យន្តការគាំទ្រដើម្បីពង្រឹងសមភាព និងការមិនរើសអើងក្នុងវិស័យអនាម័យជនបទ
# ( ភាគ ២/២ )

**Jeremy Kohlitz, Naomi Carrard** និង Juliet Willetts
សាកលវិទ្យាល័យបច្ចេកវិទ្យាស៊ីដនី – វិទ្យាស្ថានដើម្បីអនាគតប្រកបដោយនិរន្តរភាព

ការដកស្រង់ត្រឹមត្រូវ៖ កោះលីត្យូ,. ច., ខារ៉ាដ្ត, ន. និងវ៉ីលែត, ច. (២០១៩) 'យន្តការគាំទ្រដើម្បីពង្រឹងសមភាព និងការមិនរើសអើង (EQND) ក្នុងអនាម័យជនបទ (ភាគ២/២)', ព្រំដែននៃកម្មវិធីសហគមន៍ដឹកនាំអនាម័យទាំងស្រុង៖ នវានុវត្តន៍ និងចំណេះដឹង ១៣, ប្រាយតុន៖ IDS, DOI: 10.19088/SLH.2020.003

បោះពុម្ពលើកទី ១ នៅឆ្នាំ ២០១៩
រក្សាសិទ្ធិថតចម្លង©វិទ្យាស្ថានសិក្សាអភិវឌ្ឍន៍ ឆ្នាំ ២០១៩
រក្សាសិទ្ធិមួយចំនួន៖ សម្រាប់ព័ត៌មានលម្អិត សូមមើលអាជ្ញាប័ណ្ណសិទ្ធិថតចម្លង។

ISBN 978-1-78118-705-0

DOI: 10.19088/SLH.2020.003
(https://doi.org/10.19088/SLH.2020.003)

សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទង ៖
The Sanitation Learning Hub, Institute of Development Studies, University of Sussex, Brighton, BN1 9RE
Tel: +44 (0)1273 606261
Email: SLH@ids.ac.uk
Web: https://sanitationlearninghub.org/

កម្រងឯកសារនេះត្រូវបានផ្តល់អាជ្ញាប័ណ្ណក្រោមអាជ្ញាប័ណ្ណ the Creative Commons Attribution-Non-Commercial-NoDerivs 3.0 Unported License (http://creativecommons.org/licenses/by-nc-nd/3.0/)។

*ការសំអាង៖ អ្នកត្រូវសំអាងវណ្ណកម្មនេះតាមរបៀបដែលកំណត់ដោយអ្នកនិពន្ធ ឬអ្នកផ្តល់អាជ្ញាប័ណ្ណ។*
*មិនមែនសម្រាប់គោលបំណងពាណិជ្ជកម្ម៖ អ្នកប្រហែលជាមិនអាចប្រើប្រាស់វណ្ណកម្មនេះសម្រាប់គោលបំណងពាណិជ្ជកម្មបានទេ។*
*គ្មានការចម្លងតាម៖ អ្នកប្រហែលជាមិនអាចកែប្រែ ផ្ទេរ ឬផ្អែកលើវណ្ណកម្មនេះបានទេ។*

អ្នកប្រើប្រាស់អាចថតចម្លង ចែកចាយ ដាក់បង្ហាញ បកប្រែ ឬយកវណ្ណកម្មនេះទៅប្រើប្រាស់ដោយគ្មានការអនុញ្ញាតជាលាយលក្ខណ៍អក្សរ។ សម្រាប់ការប្រើប្រាស់ឡើងវិញ ឬការចែកចាយ អ្នកត្រូវបញ្ជាក់ឱ្យបានច្បាស់ពីលក្ខខណ្ឌអាជ្ញាប័ណ្ណនៃវណ្ណកម្មនេះ។ ប្រសិនបើអ្នកប្រើប្រាស់វណ្ណកម្មនេះ យើងស្នើឱ្យអ្នកយោងតាមគេហទំព័រ SLH (https://sanitationlearninghub.org) រួចបញ្ជូនសំណៅចម្លងវណ្ណកម្មនេះ ឬតំណភ្ជាប់សម្រាប់ការប្រើប្រាស់តាមអនឡាញ តាមអាសយដ្ឋាន៖ The Sanitation Learning Hub, Institute of Development Studies, University of Sussex, Brighton, BN1 9RE, UK (SLH@ids.ac.uk)។

ឯកសារនេះត្រូវបានផ្តល់ហិរញ្ញប្បទានដោយទីភ្នាក់ងារកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍អន្តរជាតិស៊ុយអែត Sida។ ទស្សនៈដែលបានលើកឡើងក្នុងក្នុងឯកសារនេះមិនសុទ្ធតែឆ្លុះបញ្ចាំងពីទស្សនៈរបស់ Sidaឡើយ។ ការទទួលខុសត្រូវលើខ្លឹមសារឯកសារនេះជាបន្ទុកទាំងស្រុងរបស់អ្នកនិពន្ធ។

# សេចក្ដីថ្លែងអំណរគុណ

អ្នកនិពន្ធសូមអរគុណដោយស្មោះចំពោះ Andy Robinson, Gabrielle Halcrow, Anne Mutta, Jamie Myers និង Naomi Vernon ដែលបានពិនិត្យឡើងវិញលើសំណេរដៃ និងផ្ដល់យោបល់ត្រឡប់។ សូមអរគុណចំពោះ Hanh Nguyen, Anne Mutta និង Louise Maule ដែលបានចែករំលែកព័ត៌មាន និងពិនិត្យឡើងវិញលើករណីសិក្សា។


UTS Institute for Sustainable Futures

# យន្តការគាំទ្រដើម្បីពង្រឹងសមភាព និងការមិនរើសអើងក្នុងវិស័យអនាម័យជនបទ
## ( ភាគ ២/២ )

## សេចក្តីផ្តើម

ការផ្តោតជាថ្មីលើសមធម៌ កំពុងត្រូវបានជំរុញដោយក្របខណ្ឌសិទ្ធិមនុស្សក្នុងការទទួលបានទឹកស្អាត និងអនាម័យ និងគោលដៅទី៦.២ នៃការអភិវឌ្ឍប្រកបដោយចីរភាព ដែលផ្តោតសំខាន់លើសារៈសំខាន់លើការទទួលបានអនាម័យគ្រប់គ្រាន់ និងប្រកបដោយសមធម៌សម្រាប់មនុស្សគ្រប់រូប។ កម្មវិធីសហគមន៍ដឹកនាំអនាម័យទាំងស្រុង (CLTS) ផ្អែកលើការយល់ថា ការកែលម្អជាសមូហភាព និងមាននិរន្តរភាពក្នុងសកម្មភាពអនាម័យមានប្រសិទ្ធភាពបំផុតនៅពេលដែលសហគមន៍កំណត់រក និងជំរុញដំណោះស្រាយអនាម័យរបស់ខ្លួន ដោយផ្អែកតាមរបាយនៃការប្រើប្រាស់បង្គន់មិនស្មើគ្នា នៅទូទាំងពិភពលោក។ ក្នុងផ្នែកទី ១ នៃឯកសារនេះ (សមភាព និងការមិនរើសអើង) ភស្តុតាងបង្ហាញថា ដំណើការសហគមន៍ដឹកនាំអនាម័យទាំងស្រុង សម្រាប់ការសម្រេចបានលទ្ធផលទូទាំងសហគមន៍ មិនសុទ្ធតែមានលក្ខណៈជាប្រព័ន្ធ គ្រប់គ្រាន់អាចរក្សាបានឬអាចបំពេញតម្រូវការរបស់ក្រុមជួបការលំបាកបាននោះទេ (House et al. 2017)។

ដើម្បីធានាលទ្ធផលប្រកបដោយសមធម៌ មានការផ្តោតការយកចិត្តទុកដាក់កាន់តែខ្លាំងលើយន្តការគាំទ្រផ្សេងទៀត ដែលបំពេញបន្ថែមឱ្យដំណើរការធម្មតានៃការបង្កើតតម្រូវការ ការផ្លាស់ប្តូរឥរិយាបថ ការបង្កើនសិទ្ធិអំណាចរបស់សហគមន៍ និងសកម្មភាពក្នុងសហគមន៍។ ទោះបីជាគំនិតបង្កើតយន្តការគាំទ្រផ្សេងទៀត សម្រាប់កម្មវិធីសហគមន៍ដឹកនាំអនាម័យទាំងស្រុងមិនមែនជាអ្វីដែលថ្មីក្តី (Papafilippou et al. 2011) ប៉ុន្តែការអនុវត្តយន្តការនេះជាប្រព័ន្ធមិនសូវមានវិធីសាស្ត្ររៀបចំកម្មវិធីសហគមន៍ដឹកនាំអនាម័យទាំងស្រុង និងកម្មវិធីអនាម័យនោះទេ។ យន្តការគាំទ្រកាន់តែមានសារៈសំខាន់ខ្លាំងឡើង ព្រោះមានភស្តុតាងបង្ហាញថា ក្នុងកាលៈទេសៈមួយចំនួន គ្រួសារជួបការលំបាកច្រើនតែងាកទៅរកការបន្ទោរបង់ពាសវាលពាសកាល ឬមិនបានសង់ និងប្រើប្រាស់បង្គន់ដែលមានគុណភាពល្អតាំងពីដំបូង (Cavill et al. 2016; Robinson and Gnilo 2016)។ ដូច្នេះចាំបាច់ត្រូវមាន "វិធីសាស្ត្រអព្យាក្រឹត្យ" ក្នុងការរក្សាតុល្យភាពនៃការបង្កើនសិទ្ធិអំណាច និងការផ្លាស់ប្តូរឥរិយាបថ ដោយមានការអនុវត្តទម្រង់នៃការគាំទ្រ យ៉ាងប្រុងប្រយ័ត្ន (Willets and Powell 2016)។

ដំណើរការសហគមន៍ដឹកនាំអនាម័យទាំងស្រុងកន្លងមក ប្រហែលជាមិនសុទ្ធតែត្រូវការយន្តការគាំទ្របន្ថែមដើម្បីបង្កើតលទ្ធផលដែលមានសមធម៌នោះទេ ព្រោះកម្មវិធីសហគមន៍ដឹកនាំអនាម័យទាំងស្រុង អាចមានប្រសិទ្ធភាពក្នុងការសម្រេចបានលទ្ធផលទូទាំងសហគមន៍ ជាពិសេសប្រសិនបើមានស្ថានភាពអំណោយផល (សូមមើល Kar and Chambers 2008)។ ប៉ុន្តែ ភស្តុតាងបង្ហាញថា ការរៀបចំកម្មវិធីអនាម័យជនបទជារួម ត្រូវតែមានលក្ខណៈលាយឡំគ្នា និងពិចារណាពីកម្រិតដែលយុទ្ធសាស្ត្រគាំទ្រអាចស៊ីសង្វាក់គ្នាទៅនឹងបរិបទជាក់លាក់។

## ការកំណត់និយមន័យ "ការគាំទ្រ"

ក្នុងឯកសារនេះ យើងប្រើប្រាស់និយមន័យដ៏ទូលំទូលាយមួយនៃ "ការគាំទ្រ" សម្រាប់ការបង្កើតលទ្ធផលដែលមានសមធម៌។ ទោះបីជាពាក្យនេះច្រើនសំដៅលើការឧបត្ថម្ភថវិកា និងសម្ភារៈក្តី ប៉ុន្តែការយល់ដឹងជាក់ស្តែង ពីការគាំទ្រ ត្រូវរួមបញ្ចូលទាំងយន្តការ "ផ្នែករឹង" និងវិធីសាស្រ្ត "ផ្នែកធន់" និងការរួមបញ្ចូលសមាសភាគទាំងពីរនេះ (Myers et al. 2017; ISF-UTS and SNV 2018)។



ថ្មីៗនេះ គណៈកម្មាធិការអភិវឌ្ឍន៍ភូមិ បានជួយដល់ជនជាតិ Tabieni ក្នុងការសង់បង្គន់ (ប្រទេសម៉ាឡាវី)។
ក្រេឌីត ៖ WSSCC/Suzanne Ferron



ម្ចាស់បង្គន់ថ្មីមានមោទនភាព ដែលបានទទួលថវិកាបង្វិលសងវិញដើម្បីកាត់បន្ថយចំណាយលើការសង់បង្គន់ថ្មី (តំបន់ទន្លេមេគង្គ ប្រទេសវៀតណាម)។ ក្រេឌីត ៖ Juliet Willetts

ការគាំទ្រអាចមានប្រភពពីកម្រិតទាំងអស់នៃរដ្ឋាភបាល អង្គការសង្គមស៊ីវិលមូលដ្ឋាន ឬអង្គការសង្គមស៊ីវិលអន្តរជាតិ ក្នុងសហគមន៍បណ្តាញគ្រួសារ (ក្នុង និងក្រៅសហគមន៍) និងទីភ្នាក់ងារអភិវឌ្ឍន៍ (ISF-UTS and SNV 2018)។ វិធីសាស្រ្តសហគមន៍ដឹកនាំអនាម័យទាំងស្រុងកន្លងមកតែងជំរុញឱ្យមានការគាំទ្រក្នុងសហគមន៍តាមរយៈគ្រួសារក្នុងសហគមន៍ដែលបរិច្ចាគដី សម្ភារៈ និងកម្លាំងពលកម្មដល់សមាជិកក្នុងសហគមន៍ដែលខ្វះខាត (Musembi and Musyoki 2016 សូមមើលផងដែរ រូបភាពខាងលើ)។ ទោះជាយ៉ាងណា នៅតែមានវិសាលភាពសម្រាប់ឱ្យកម្មវិធីអនាម័យជនបទ អនុវត្តយន្តការគាំទ្រជាច្រើនដូចជា យន្តការគាំទ្រតាមស្ថាប័ន ដែលមានលើកឡើងក្នុងឯកសារនេះ។

យើងពិចារណាថា ការគាំទ្រនឹងរួមបញ្ចូលបណ្តុំយន្តការ ជំនួយថវិកា ជំនួយសម្ភារៈ និងជំនួយមិនមែនសម្ភារៈ ដែលគ្របដណ្តប់លើសពីដំណើរការគាំទ្រសហគមន៍ដឹកនាំអនាម័យទាំងស្រុងកន្លងមក (ប៉ុន្តែ ច្រើនតែលាយឡំ ជាមួយសមាសភាគទាំងនេះ)។ យើងផ្តោតការយកចិត្តទុកដាក់លើរបៀបរៀបចំយន្តការទាំងនេះ ដើម្បីលើកឡើងពីបញ្ហាប្រឈមរបស់ជន និងក្រុមជួបការលំបាក។ រូប១ បង្ហាញពីយន្តការគាំទ្រជាច្រើន។ ការដាក់បញ្ចូល យន្តការគាំទ្រក្នុងយុទ្ធសាស្រ្តគោលនយោបាយ ថវិកា និងដំណើរការពិនិត្យតាមដានរបស់រដ្ឋាភិបាល និងស្ថាប័នផ្សេងទៀត ជាកត្តាដ៏សំខាន់ក្នុងការផ្លាស់ប្តូរពីការផ្តោតលើគម្រោង ស្តីពីសមធម៌ ទៅជាការផ្តោតលើស្ថាប័នដែលជាចំណុចស្នូលក្នុងរូប១។ ដូច្នេះរដ្ឋាភិបាលមូលដ្ឋាននឹងក្លាយជាតួអង្គស្នូលដែលជំរុញដំណើរការនេះ។

**រូប ១៖** យន្តការគាំទ្រនានាដែលអ្នកអនុវត្តន៍កម្មវិធីអនាម័យជនបទអាចយកទៅប្រើប្រាស់ដើម្បីជួយដល់ ប្រ

ផ្តល់ប័ណ្ណបញ្ចុះតម្លៃដើម្បីទិញផលិតផលមួយក្នុងទីផ្សារ ក្នុងករណីមួយចំនួនដោយមានការបង្វិលសងថវិកាវិញ (ពីរដ្ឋាភិបាល ឬតួអង្គផ្សេងទៀត) ដល់អ្នកផ្គត់ផ្គង់ឯកជនដើម្បីលើកទឹកចិត្តដល់ការចូលដល់ក្រុមជួបការលំបាក។



អាជីវ ក

តស៊ូមតិ និងផ្តល់ព័ត៌មានពីវិធីសាស្ត្រសម្រាប់គាំទ្រដល់ក្រុមជួបការលំបាក ក្នុងការទទួលបានអនាម័យដោយផ្អែកលើភស្តុតាង ដូចជា ការជំរុញការចូលរួមរបស់អ្នកមានកាតព្វកិច្ចក្នុងការប្រមូលភស្តុតាងសម្រាប់កសាងការលើកទឹកចិត្ត និងការប្តេជ្ញាចិត្ត។

បង្កើតយន្តការតាមស្ថា
ការលំបាកក្នុងគោលការ
កម្មវិធី និងថវិកាសម្រាប់
និងតួអង្គក្នុងមូល



រដ្ឋាភិបាលមូល
អ្នកជំរុញជំ

ធ្វើការស្រាវជ្រាវបណ្តើរៗ ជាមួយក្រុមផ្សេងៗ និងផ្អែកលើបទពិសោធន៍មូលដ្ឋានដើម្បីកែសម្រួលការកៀរគរក្នុងសង្គម ទំនាក់ទំនងដើម្បីផ្លាស់ប្តូរឥរិយាបថ និងអន្តរាគមន៍បង្កើតតម្រូវការ ឱ្យឆ្លុះបញ្ចាំងពីតម្រូវការ និងបញ្ហាប្រឈមរបស់ក្រុមជួបការលំបាកក្នុងតំបន់ជាក់លាក់



អ្នកដឹកនាំសហគមន៍

លើកកម្ពស់បច្ចេកវិទ្យាអនាម័យបរិយាប័ន្ន ដែលសម្រួលដល់តម្រូវការរបស់ស្ត្រី ជនពិការ និងក្រុមផ្សេងទៀត និងគាំទ្រអ្នកអនុវត្តន៍ និងជាងសំណង់ក្នុងការរចនា និងសង់បង្គន់ដោយប្រើបច្ចេកវិទ្យាទាំងនេះ

លើកទឹកចិត្ត ឬជំរុញឱ្យអ្នកដឹកនាំមូលដ្ឋានកៀរគរធនធាន និងកម្លាំងពលកម្មពីសហគមន៍មូលដ្ឋានដើម្បីជួយដល់គ្រួសារជួបការលំបាកដែលគ្មានលទ្ធភាពទទួលបានអនាម័យ និងតាមដានវឌ្ឍនភាព ឬសម្របសម្រួលយន្តការគាំទ្រផ្សេងទៀត

**យន្តការគាំទ្រ ន**
**ប្រើប្រាស់រួម ប**

ប្រភព៖ ដកស្រង់ពី ISF-UTS and SNV 2018; WASHPaLS 2018; Willetts and Powell 2016

ប់ ក្រុមជួបការលំបាក



ផ្តល់សំណងថវិកាដល់គ្រួសារបន្ទាប់ពីការ
សងបង្គន់ត្រូវបានផ្ទៀងផ្ទាត់។ ការផ្ទេរថវិកាជាមុន
ឬការផ្ទេរជាសម្ភារៈដល់គ្រួសារនោះ។

រ កម្ម

លើកទឹកចិត្តឱ្យមានគំរូអាជីវកម្មបរិយាប័ន្នដែល
ធ្វើទីផ្សារផលិតផល និងសេវាដែលមានតម្លៃសមរម្យ
ដែលបំពេញតម្រូវការរបស់ស្ត្រី ជនពិការ
ឬក្រុមផ្សេងទៀត និងពិចារណាពីផលិតផល
និងសេវាអន្តរជំនួយ ដើម្បីធានាបរិយាប័ន្ន

ា ប័នសម្រាប់គាំទ្រក្រុមជួប
ារ ណ៍ណែនាំ យុទ្ធសាស្ត្រ
ប់ អនាម័យរបស់រដ្ឋាភិបាល
ប ដ្ឋានផ្សេងទៀត



ប ដ្ឋាននឹងក្លាយជា
ដំ ណើរការនេះ

សម្របសម្រួលឥណទានខ្នាតតូចដែល (ដោយ
មាន ឬគ្មានការឧបត្ថម្ភ) តាមរយៈគ្រឹះស្ថាន
មីក្រូហិរញ្ញវត្ថុ សហករណ៍មូលដ្ឋាន
ឬក្រុមជួយខ្លួនឯង/ក្រុមសន្សំក្នុងសហគមន៍



សង្គមស៊ីវិល

បង្កើតសមាគមសន្សំ
និងសមាគមឥណទាន
រួមទាំងមូលនិធិបង្វិល

ទ នានាសម្រាប់
ទ បញ្ចូលគ្នា

ជំរុញការចូលរួមរបស់អង្គការសង្គម
ស៊ីវិល ក្រុមសហគមន៍ និងអង្គការផ្សេង
ទៀតដែលមានឯកទេសលើការតស៊ូមតិ
សម្រាប់ក្រុមជួបការលំបាកក្នុងពេល
រៀបចំផែនការ អនុវត្ត និង
ពិនិត្យតាមដានគម្រោងអនាម័យ

## ការពង្រឹងភស្តុតាង

ទោះជាអាចជឿបានថា ចាំបាច់ត្រូវមានការគាំទ្រគោលដៅសម្រាប់ជន និងក្រុមជួបការលំបាកក្តី ប៉ុន្តែភស្តុតាងនេះផ្អែកលើការងារដែលត្រូវពង្រឹង។ ការឧបត្ថម្ភថវិកា និងសម្ភារៈ ដែលជាយន្តការគាំទ្រទូទៅបំផុតពីរ មានលក្ខណៈប្រឈមគ្នាក្នុងវិស័យទឹកស្អាត និងអនាម័យ ដោយសារការព្រួយបារម្ភពីអំពើពុករលួយដោយក្រុមឥស្សរៈជន និងការព្រួយបារម្ភថា ការគាំទ្រខាងក្រោមនឹងរាំងស្ទះដល់ការជួយខ្លួនឯង ព្រោះវានឹងបង្កើតជាការរំពឹងទុកពីការជួយឧបត្ថម្ភ (WASHPaLS 2018) និងមានភស្តុតាងតិចតួចដែលបង្ហាញ ពីប្រសិទ្ធិភាពនៃការឧបត្ថម្ភទាំងនេះ (Venkataramanan et al. 2018; WASHPaLS 2018)។

មានការចងក្រងកម្មវិធីអនាម័យជនបទ និងកម្មវិធីសហគមន៍ដឹកនាំអនាម័យទាំងស្រុងចំនួន ៥០ នៅជុំវិញពិភពលោកដែលប្រើប្រាស់យន្តការគាំទ្រជាច្រើន សម្រាប់ផ្តល់មូលដ្ឋានព័ត៌មានដល់ការរៀបចំឯកសារនេះ[1]។ ការពិនិត្យឡើងវិញរហ័សលើកម្មវិធីទាំងនេះបង្ហាញថា ទោះបីជាមានការសាកល្បងជាច្រើនក្តី ប៉ុន្តែមានកម្មវិធីតិចតួចប៉ុណ្ណោះដែលត្រូវបានពង្រីក ហើយកម្មវិធីមួយចំនួនទៀតត្រូវបានអនុវត្តនៅក្រៅតំបន់អាស៊ី។ ក្រៅពីនេះ កម្មវិធីជាច្រើនមិនបានបែងចែកព័ត៌មានពិនិត្យតាមដាន និងវាយតម្លៃសម្រាប់ការចែករំលែក ឬចងក្រងជាសាធារណៈទេ។

ដូច្នេះ ឯកសារនេះផ្តោតសំខាន់លើសារៈសំខាន់នៃ**ដំណើរការពិនិត្យតាមដានវាយតម្លៃ និងការចែករំលែកចំណេះ**ដឹងដើម្បីកសាងមូលដ្ឋានភស្តុតាង សម្រាប់ការសម្រេចបានលទ្ធផលអនាម័យជនបទប្រកបដោយសមធម៌។ ដំណើរការទាំងនេះនឹងជួយដល់ការកែសម្រួលកម្មវិធីតាមវិធី ៣ យ៉ាងដូចខាងក្រោម៖

- ទីមួយ ការទទួលបានបណ្តុំយន្តការគាំទ្រត្រឹមត្រូវ ដែលចូលដល់ប្រជាជនដែលខ្វះខាតពិតប្រាកដក្នុងមជ្ឈដ្ឋានជាក់លាក់ អាចតម្រូវឱ្យមានការសាកល្បង និងការកែសម្រួលក្រោមការពិនិត្យតាមដាន និងការវាយតម្លៃជិតដល់។
- ទីពីរ មានហានិភ័យដែលយន្តការគាំទ្រមួយចំនួន ជាពិសេសការឧបត្ថម្ភថវិកា ឬសម្ភារៈ អាចរាំងស្ទះដល់ការបង្កើតតម្រូវការ និងត្រូវកំណត់រកបញ្ហានេះឱ្យបានឆាប់បំផុត។
- ទីបី ចាំបាច់ត្រូវមានការពិនិត្យតាមដានក្នុងរយៈពេលវែង ដើម្បីធានាលទ្ធផលប្រកបដោយសមធម៌។ គម្រោងអនាម័យជនបទគួរឆ្លងកាត់ការវាយតម្លៃធៀបនឹងគោលបំណងនៃការចូលដល់ក្រុមជួបការលំបាក ស្របតាមចំណុចដៅទី ៦.២ នៃគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព ស្តីពីអនាម័យប្រកបដោយសមធម៌សម្រាប់ជនគ្រប់រូប *"ដោយផ្តោតការយកចិត្តទុកដាក់ជាពិសេសលើតម្រូវការរបស់ស្ត្រី និងក្មេងស្រី និងអ្នកដែលស្ថិតក្នុងស្ថានភាពងាយរងគ្រោះ"*។

---

[1] ចងក្រងដោយ Andy Robinson និង Jamie Myers

# ការពិចារណាពីលទ្ធផលចុងក្រោយជាមុនសិន៖ ការត្រៀមខ្លួនដើម្បីភាពជោគជ័យ

មុននឹងអនុវត្តកម្មវិធី ឬសេវា ប្រការសំខាន់ត្រូវ៖

**ជំហានទី១៖** កំណត់ចំណុចដែលកម្មវិធីចង់សម្រេចបានពាក់ព័ន្ធនឹងសមធម៌ និងបរិយាប័ន្ន (ឧ. កំណត់លក្ខណៈនៃភាពជោគជ័យ)។

**ជំហានទី២៖** គ្រោងយុទ្ធសាស្ត្រសម្រាប់ការកំណត់អត្តសញ្ញាណបុគ្គល និងក្រុមដែលអាចនឹងត្រូវការជំនួយ។

**ជំហានទី៣៖** អនុវត្តយន្តការគាំទ្រចម្រុះ

**ជំហានទី៤៖** បង្កើតប្រព័ន្ធពិនិត្យតាមដានដែលតាមដានវឌ្ឍនភាព ឆ្ពោះទៅសម្រេចបានគោលបំណង។

**ជំហានទី៥៖** បង្កើតដំណើរការសម្រាប់ការចែករំលែកចំណេះដឹង និងការរៀនសូត្រ។

ជំហាននីមួយៗត្រូវបានលើកមកពិភាក្សាក្នុងផ្នែកដូចខាងក្រោម។

## ជំហានទី១៖ ការកំណត់លក្ខណៈនៃភាពជោគជ័យ

ភស្តុតាងថ្មីៗ និងខ្លឹមសារជាក់លាក់ក្នុងចំណុចដៅទី ៦.២ នៃគោលដៅអភិវឌ្ឍន៍ប្រកបដោយ ចីរភាពផ្តោតសំខាន់ លើសារៈសំខាន់នៃស្ថានភាពគ្មានការបន្ទោរបង់ពាសវាលពាសកាលទូទាំងសហគមន៍ និងអនាម័យដែលគ្រប់គ្រងដោយសុវត្ថិភាព រួមទាំងសម្រាប់ក្រុមជួបការលំបាក។ គោលការណ៍ណែនាំឆ្នាំ ២០១៨ របស់អង្គការសុខភាពពិភពលោកស្តីពីអនាម័យ និងសុខភាព លើកឡើងថា *"អន្តរាគមន៍អនាម័យគួរធានាការគ្របដណ្តប់លើសហគមន៍ទាំងមូល យ៉ាងហោចណាស់មានបង្គន់សុវត្ថិភាព ដែលអាចគ្រប់គ្រងការបញ្ចេញចោលរបស់មនុស្សដោយសុវត្ថិភាព និងលើកឡើងពីឧបសគ្គផ្នែកបច្ចេកវិទ្យា និងឥរិយាបថក្នុងការប្រើប្រាស់"* (WHO 2018)។ ក្រៅពីនេះ សហគមន៍ទាំងមូលត្រូវប្រើបង្គន់ឱ្យបានជាប់លាប់ ដើម្បីកែលម្អ ស្ថានភាពបរិស្ថាន និងបង្កើនអត្ថប្រយោជន៍សុខភាព (Cronin et al. 2017; Cumming and Curtis 2018)។ ដូច្នេះសំខាន់បំផុតត្រូវ បញ្ជាក់ថាបង្គន់ពិតជាត្រូវបានប្រើប្រាស់ដោយមនុស្សគ្រប់រូបមិនមែនគ្រាន់តែសង់ចោលនោះទេ។



ការស្រាវជ្រាវបន្ថែម ដែលឆ្លុះបញ្ចាំងពីបទពិសោធន៍នៃកម្មវិធីអនាម័យជនបទក្នុងប្រទេស ៥ បានគូសបញ្ជាក់ពីសារៈសំខាន់នៃការរៀបចំយន្តការគាំទ្រយ៉ាងយកចិត្តទុកដាក់ដើម្បីពង្រឹងដំណើរការក្នុងប្រទេស និងបញ្ចៀសផលប៉ះពាល់អវិជ្ជមាន (ISF-UTS and SNV 2018)។ ផ្អែកលើការរៀនសូត្រថ្មីៗទាំងនេះ យើងបានកត់សម្គាល់កត្តាកំណត់ភាពជោគជ័យ ៥ ដើម្បីឱ្យយន្តការគាំទ្រធានាវិសាលភាពទាំងស្រុង៖

១. មនុស្សគ្រប់រូប រួមទាំងក្រុមជួបការលំបាក អាចទទួលបានហេដ្ឋារចនាសម្ព័ន្ធអនាម័យដែលសមស្រប និងអាចទទួលយកបាន។

២. មនុស្សគ្រប់រូបប្រើប្រាស់ហេដ្ឋារចនាសម្ព័ន្ធអនាម័យជាប់លាប់។

៣. យន្តការគាំទ្រត្រូវបានបញ្ជ្រាបក្នុងស្ថាប័នរដ្ឋាភិបាល ដំណើរការឯកជន និងដំណើរការរបស់វិស័យផ្សេងទៀត។

៤. យន្តការឧបត្ថម្ភថវិកា ឬសម្ភារៈ ដើម្បីបង្កើនលទ្ធភាពទទួលបានអនាម័យក្នុងតំបន់មួយ មិនសុទ្ធតែរាំងស្ទះដល់វឌ្ឍនភាពក្នុងតំបន់ផ្សេងទៀត ឬទីផ្សារទឹកស្អាត និងអនាម័យឡើយ។

៥. ចំណាយលើយន្តការគាំទ្រ មិនមែនជាកត្តារាំងស្ទះដល់ការពង្រីកយន្តការនេះឡើយ។

## ជំហានទី២៖ ការកំណត់វិសាលភាព និងការកំណត់អត្តសញ្ញាណក្រុមជួបការលំបាក

ការធានាសមភាព និងការមិនរើសអើងក្នុងសកម្មភាពអនាម័យ តម្រូវឱ្យទីភ្នាក់ងារគាំទ្រកំណត់អត្តសញ្ញាណជនជួបការលំបាកក្នុងការទទួលបានអនាម័យ (Roaf et al. 2018)។ ដូចការរៀបរាប់ក្នុងផ្នែកទី១ នៃឯកសារនេះ ចាំបាច់ត្រូវមានការកំណត់អត្តសញ្ញាណជន និងក្រុមជួបការលំបាកយ៉ាងត្រឹមត្រូវ ដើម្បីកាត់បន្ថយហានិភ័យ និងដោះស្រាយឧបសគ្គរាំងជន/ក្រុមជួបការលំបាកក្នុងការសាងសង់ និងថែទាំជួសជុលបង្គន់ បូករួមនឹងការពនិត្យតាមដានលទ្ធផលសម្រាប់ក្រុមជាក់លាក់ទាំងនេះ (House et al. 2017)។




ការជំរុញឱ្យបុគ្គលសំខាន់ៗក្នុងមូលដ្ឋានចូលរួមក្នុងដំណើរការនេះ។ ក្រេឌីត ៖ WEDC/Rod Shaw

## ការពង្រឹងភស្តុតាង

ក្រុមដែលត្រូវបានកំណត់អត្តសញ្ញាណទូទៅជាក្រុមជួបការលំបាក អាចនឹងទាមទារ ឬមិនទាមទារការគាំទ្រក្នុងការសាងសង់ ប្រើប្រាស់ ឬថែទាំជួសជុលបង្គន់ (House et al. 2017)។ អ្នកដែលទាមទារការគាំទ្រអាចត្រូវបានគេមើលរំលង ប្រសិនបើលក្ខណៈវិនិច្ឆ័យនៃលក្ខណៈសម្បត្តិសម្រាប់ទទួលបានការគាំទ្រ គ្មានលក្ខណៈបរិយាប័ន្នគ្រប់គ្រាន់ ឬក៏មានឧបសគ្គជាច្រើនរារាំងការចូលរួម (ឧ. ប្រសិនបើការចូលរួមតម្រូវឱ្យពួកគេចេះអក្សរ ឬចំណាយលើការធ្វើដំណើរទៅទីតាំងគម្រោង)។ ពាក់ព័ន្ធនឹងការដោះស្រាយកំហុសឆ្គងនៃការរួមបញ្ចូល និងការផាត់ចេញ ចាំបាច់ត្រូវផ្អែកតាមមេរៀន ៣ នៅពេលកំណត់អត្តសញ្ញាណអ្នកដែលត្រូវការគាំទ្រសម្រាប់ការទទួលបានអនាម័យ (ISF-UTS and SNV 2018)៖

- ដេញដោលការសន្មត និងផ្អែកលើភស្តុតាងស្តីពីអ្នកដែលត្រូវការការគាំទ្រដើម្បីធានាថា គ្មានការផាត់ចេញនរណាម្នាក់ និងជួយដល់ការកំណត់អាទិភាពនៃយុទ្ធសាស្ត្រគាំទ្រ។
- ប្រើប្រាស់វិធីសាស្ត្រផ្សេងៗ ក្នុងការកំណត់អត្តសញ្ញាណ ក្រុមជួបការលំបាក ប្រកបដោយភាពសាមញ្ញ តម្លាភាព និងភាពគ្រប់ជ្រុងជ្រោយដើម្បីរួមបញ្ចូល និងគាំទ្រឱ្យបុគ្គលដែលមានលក្ខណៈសម្បត្តិអាចទទួលបានយន្តការគាំទ្រ ប៉ុន្តែមិនធ្វើឱ្យវិធីសាស្ត្រនេះស្មុគស្មាញខ្លាំង។
- ការកំណត់អត្តសញ្ញាណក្រុមជួបការលំបាក មិនគួរជាដំណើរការដាច់ដោយឡែកមួយនោះទេ ប៉ុន្តែដំណើរការនេះគួរត្រូវបានកែសម្រួលឡើងវិញ និងទទួលបានការយកចិត្តទុកដាក់ ក្នុងពេលអនុវត្តកម្មវិធី។



ការពិគ្រោះយោបល់ជាមួយបុរស និងស្ត្រីចំណាស់ក្នុងទីក្រុងកាត់ម៉ាន់ឌូ ប្រទេសនេប៉ាល់។
*ក្រេឌីត ៖ WSSCC/Javier Acebal*



ស្ត្រីកំពុងចូលរួមក្នុងព្រឹត្តិការណ៍បំផុសសហគមន៍ដឹកនាំអនាម័យទាំងស្រុងក្នុងតំបន់រដ្ឋាភិបាលមូលដ្ឋាន Obanliku ប្រទេសនីហ្សេរីយ៉ា។
*ក្រេឌីត ៖ United Purpose/Jason Florio*

តារាង ១ រៀបរាប់ពីមធ្យោបាយផ្សេងៗក្នុងការកំណត់អត្តសញ្ញាណក្រុមជួបការលំបាក និងគុណសម្បត្តិ និងគុណវិបត្តិនៃមធ្យោបាយទាំងនោះ។

## តារាង ១៖ មធ្យោបាយកំណត់អត្តសញ្ញាណក្រុមជួបការលំបាក

| មធ្យោបាយ | គុណសម្បត្តិ |
|---|---|
| ប្រើប្រាស់ប្រភពទិន្នន័យមានស្រាប់ (ឧ. ទិន្នន័យជំរឿនការអង្កេតសុខភាពប្រជាសាស្ត្រ ឬប្រព័ន្ធកំណត់អត្តសញ្ញាណភាពក្រីក្រ) (សូមមើលករណីសិក្សាទី ១ នៅទំព័រ....) | • ការតម្រឹមតម្រង់តាមប្រភពទិន្នន័យរបស់រដ្ឋាភិបាល នឹងសម្រួលដល់ការតម្រឹមតម្រង់តាមកម្មវិធីកាត់បន្ថយភាពក្រីក្រ និងកម្មវិធីគាំពារសង្គមដែលមានស្រាប់។<br>• អាចពាក់ព័ន្ធជាមួយ និងកែលម្អប្រព័ន្ធពិនិត្យតាមដានរបស់រដ្ឋាភិបាល<br>• អាចផ្តល់ប្រភេទច្បាស់លាស់នៃបុគ្គលដែលនឹងទទួលបាន ឬនឹងមិនទទួលបានការគាំទ្រ<br>• ការប្រើប្រាស់ការអង្កេតតាមស្តង់ដារអន្តរជាតិ នឹងធានានូវវិធីសាស្ត្ររួមតាមបណ្តាប្រទេសនានា។ |
| ការវាយតម្លៃដោយឯករាជ្យលើប្រាក់ចំណូលទ្រព្យសម្បត្តិ ឬលក្ខណៈផ្សេងទៀតរបស់គ្រួសារ (ឧ. ការចុះតាមគ្រួសារ ឬការប៉ាន់ប្រមាណគ្រួសារនៅពេលពួកគេស្នើសុំការគាំទ្រ) (សូមមើលករណីសិក្សាទី ២ នៅទំព័រ.....) | • ផ្តល់លទ្ធភាពឱ្យមានការប្រើប្រាស់វិធីសាស្ត្រដែលល្អិតល្អន់និងកែសម្រួលទៅតាមបរិបទជាក់លាក់<br>• ការវាយតម្លៃជាក់ស្តែងលើទ្រព្យសម្បត្តិអាចកាន់តែមានភាពប្រាកដប្រជា និងត្រឹមត្រូវជាងស្វ័យរាយការណ៍ពីប្រាក់ចំណូល<br>• អាចជួយកំណត់រកវិសមភាពក្នុងគ្រួសារ |
| សម្របសម្រួលការវាយតម្លៃដោយខ្លួនឯងដែលដឹកនាំដោយសហគមន៍ (ឬដឹកនាំដោយរដ្ឋាភិបាលមូលដ្ឋាន) | • លើកកម្ពស់តម្លាភាព និងស្វ័យសម្រេចចិត្តនៅកម្រិតសហគមន៍<br>• វាយតម្លៃចំណេះដឹងនៅមូលដ្ឋានស្តីពីវិសមភាព និងគុណវិបត្តិ<br>• សម្រួលដល់វិធីសាស្ត្រផ្អែកតាមការមូលមតិគ្នា ដើម្បីផ្តល់ផ្គង់ការគាំទ្រដែលមានទៅនឹងតម្រូវការ |
| សហការជាមួយអង្គការមូលដ្ឋាន (ឧ.ក្រុមគស្ម៊ូមតិគាំទ្រជនពិការដែលស្គាល់សហគមន៍មូលដ្ឋានច្បាស់) | • ផ្អែកលើជំនាញក្នុងមូលដ្ឋាន និងចំណេះដឹងរបស់សហគមន៍ស្តីពីជនដែលអាចជួបការលំបាក |
| ការកំណត់ទីតាំងភូមិសាស្ត្រ/តំបន់គោលដៅ (ឧ.ការកំណត់រកតំបន់ដែលគេចាត់ទុកថា សំបូរគ្រួសារក្រីក្រ) | • ងាយបង្កើតព្រំប្រទល់តំបន់សម្រាប់អ្នកដែលនឹងទទួលបានការគាំទ្រ<br>• ជាវិធីសាស្ត្រដែលចំណាយតិច និងអាចពង្រីកបាន |
| ផ្តល់ការគាំទ្រដែលមានភាពទាក់ទាញទាំងចំពោះអ្នកដែលខ្វះខាតពិតប្រាកដ (ឧ. ការឧបត្ថម្ភសម្ភារៈសម្រាប់ការសង់បង្គន់រណ្តៅធម្មតាក្នុងតំបន់ដែលគ្រួសារស្តុកស្តម្ភចង់បានអាងទឹកស្អុយ)។ | • មានកំហុសឆ្គងតិចតួចពាក់ព័ន្ធនឹងការរួមបញ្ចូល (អ្នកដែលមិនត្រូវការជំនួយ) |

ប្រភព ៖ ដកស្រង់ចេញពី ISF-UTS (2016), Jenkins and Pedi (2013), and WASHPaLS (2018)

| គុណវិបត្តិ |
| --- |
| • ប្រភពរបស់រដ្ឋាភិបាលអាចផ្តោតតែលើវិសមភាពសេដ្ឋកិច្ច។<br>• និយមន័យផ្លូវការនៃភាពក្រីក្រ អាចមិនឆ្លុះបញ្ចាំងត្រឹមត្រូវពីតថភាព។<br>• ទិន្នន័យអាចមានគុណភាពទាប គ្មានការផ្ទៀងផ្ទាត់ គ្មាន ឬផុតសុពលភាព។<br>• ទិន្នន័យអាចមិនត្រូវបានធ្វើបច្ចុប្បន្នភាពញឹកញាប់ |
| • ចំណាយពេលយូរ និងធនធានច្រើន និងលំបាកពង្រីក<br>• ប្រាក់ចំណូលដែលរាយការណ៍ដោយបុគ្គលផ្ទាល់អាចមិនសូវត្រឹមត្រូវ។<br>• អាចមើលរំលងអ្នកដែលមានលក្ខណៈសម្បត្តិទទួលបានការគាំទ្រប្រសិនបើពួកគេមិនចូលរួមដោយផ្ទាល់។ |
| • អាចបង្កភាពចម្រូងចម្រាស់ក្នុងសហគមន៍ ពាក់ព័ន្ធនឹងអ្នកដែលគេសន្មតថាត្រូវការជំនួយ។<br>• ទាមទារធនធានមនុស្សយ៉ាងច្រើនសម្រាប់ការរៀបចំ និងគ្រប់គ្រងដោយគិតពីអារម្មណ៍របស់អ្នកដទៃ<br>• លំបាកធ្វើប្រតិបត្តិការទ្រង់ទ្រាយធំ<br>• ហានិភ័យនៃអំពើពុករលួយដោយក្រុមឥស្សរៈជន |
| • អាចចំណាយពេលយូរ និងបង្កជាអំពើពុករលួយ ឬការអនុវត្តខុសទិសដៅ<br>• ប្រហែលជាមិនអាចពង្រីកបាន ប្រសិនបើគ្មានអង្គការដៃគូក្នុងតំបន់ភូមិសាស្ត្រទាំងអស់ |
| • ហានិភ័យកាន់តែខ្ពស់នៃការរួមបញ្ចូលអ្នកដែលមិនក្រីក្រ ឬផាត់ចេញជនក្រីក្រ ក្នុងការទទួលបានជំនួយ<br>• ផ្តោតតែលើវិសមភាពសេដ្ឋកិច្ច<br>• អាចរួមចំណែកបង្កជាការមាក់ងាយតំបន់ណាមួយ<br>• អាចធ្វើឱ្យមានការរំពឹងទុកលើការផ្តល់ជំនួយដូចគ្នាក្នុងស្រុកជិតខាង។ |
| • លំបាករចនាឱ្យមានប្រសិទ្ធភាព<br>• មិនមែនជនគ្រប់រូបដែលខ្វះខាត សុទ្ធតែអាចទទួលបានប្រយោជន៍នោះទេ។ |

## ជំហានទី ៣៖ ការអនុវត្តយន្តការគាំទ្រចម្រុះ

អាចមានយន្តការគាំទ្រជាច្រើន (សូមមើលរូប ១) ប៉ុន្តែសំខាន់បំផុតត្រូវពិចារណាពីរបៀបដែលយុទ្ធសាស្ត្រគាំទ្រនានាស៊ីសង្វាក់គ្នានឹងបរិបទជាក់លាក់។ ឧ. តំបន់ជនបទមួយចំនួននៅជិតផ្សារ និងរដ្ឋាភិបាលមូលដ្ឋាន ជាងតំបន់ជនបទផ្សេងទៀត ឬមានសម្ព័ន្ធភាពសង្គមរឹងមាំ ឬខ្សោយជាងតំបន់ផ្សេងទៀត ហើយកត្តាទាំងនេះអាចធ្វើឱ្យប៉ះពាល់ដល់ប្រសិទ្ធភាពនៃយុទ្ធសាស្ត្រគាំទ្រដែលបានជ្រើសរើស។ ឯកសារមានស្រាប់ស្តីពីយន្តការគាំទ្រផ្តោតសំខាន់លើការឧបត្ថម្ភថវិកា និងសម្ភារៈ ហើយចំណុចទាំងនេះលេចឡើងក្នុងករណីសិក្សានៃឯកសារនេះ។ ដូច្នេះ ខ្លឹមសារលម្អិតស្តីពីទម្រង់យន្តការគាំទ្រផ្សេងទៀតមានរៀបរាប់ដូចខាងក្រោម៖

**លើកទឹកចិត្តឱ្យអ្នកដឹកនាំមូលដ្ឋានកៀរគរធនធាន៖** យន្តការនេះច្រើនតែជាផ្នែកមួយនៃអន្តរាគមន៍សហគមន៍ដឹកនាំអនាម័យទាំងស្រុងបែបប្រពៃណី ប៉ុន្តែវាមិនសុទ្ធតែត្រូវបានអនុវត្តជាប្រព័ន្ធដើម្បីលើកឡើងពីក្រុមជួបការលំបាកទាំងអស់នោះទេ។ ឧទាហរណ៍មួយក្នុងប្រទេសនេប៉ាល់បង្ហាញថា ក្រៅពីការកៀរគរការគាំទ្រក្នុងមូលដ្ឋានដល់គ្រួសារដែលគ្មានលទ្ធភាពសង់បង្គន់ អាជ្ញាធរមូលដ្ឋានអាចជួលអ្នកកៀរគរសង្គមមួស្លីមឱ្យចុះតាមផ្ទះគ្រួសារមូស្លីម ដើម្បីបង្កើនការស្របទាញក្រុមអ្នកដែលមិនទទួលបានការយកចិត្តទុកដាក់ (ISF-UTS and SNV, 2018)។ គ្រឿងលើកទឹកចិត្តសម្រាប់ឱ្យអ្នកដឹកនាំមូលដ្ឋានគាំទ្រលទ្ធផលប្រកបដោយសមធម៌ ពិតជាមានប្រសិទ្ធភាព ប៉ុន្តែគួររៀបចំ និងជំរុញគ្រឿងលើកទឹកចិត្តទាំងនោះដោយប្រុងប្រយ័ត្ន។ ឧ. ការផ្តល់ការទទួលស្គាល់ផ្លូវការដល់អ្នកដឹកនាំដើម្បីបង្កើនស្ថានភាពរបស់ខ្លួន ឬក៏ការិយាល័យស្រុកអាចទទួលបានការផ្ទេរសាច់ប្រាក់ដោយមានលក្ខខណ្ឌ ដើម្បីលើកទឹកចិត្តឱ្យពួកគេសម្រេចបានលទ្ធផលអនាម័យប្រកបដោយសមធម៌ (សូមមើលករណីសិក្សាទី ១ ទំព័រ....)។

**លើកទឹកចិត្តគំរូអាជីវកម្មបរិយាប័ន្ន៖** វិស័យឯកជនអាចដើរតួនាទីសំខាន់ក្នុងការជំរុញការសង់បង្គន់ ប៉ុន្តែមិនសុទ្ធតែចាត់ទុកថា ជនក្រីក្រអាចផ្តល់ប្រាក់ចំណេញដល់ខ្លួននោះទេ។ គេអាចពង្រឹងសមធម៌ តាមរយៈការធ្វើយ៉ាងណាឱ្យអាជីវកម្មអនាម័យមានស្មារតី "ទទួលខុសត្រូវក្នុងសង្គម" និងរៀបចំផែនការអាជីវកម្ម ដែលអាចឱ្យពួកគេផ្តល់ផលិតផល និងសេវាដែលមានតម្លៃសមរម្យ (និងកែសម្រួលទៅតាមតម្រូវការ) ដោយមិនធ្វើឱ្យប៉ះពាល់ដល់ប្រាក់ចំណេញរបស់ពួកគេ។ ឧ. សូមមើលវិធីសាស្ត្ររបស់ iDE ក្នុងការធ្វើទីផ្សារអនាម័យដែលគាំទ្រជនក្រីក្រនៅកម្ពុជា (iDE, n.d.)។ ក្នុងករណីមួយចំនួន ប្រហែលជាត្រូវមានអន្តរាគមន៍ពីរដ្ឋាភិបាលដើម្បីជួយផ្តល់ការគាំទ្រ ឬគ្រឿងលើកទឹកចិត្តឱ្យអាជីវកម្មចូលដល់ក្រុមជួបការលំបាក (ជាពិសេសក្នុងករណីដែលតំបន់ដាច់ស្រយាលមានបញ្ហាសេដ្ឋកិច្ច) (Gero and Willetts, 2019)។



ការសង់បង្គន់សម្រាប់ជនពិការក្នុងទីក្រុង ដាកា ប្រទេសបង់ក្លាដេស។
*ក្រេឌីត៖ Juliet Willets*



"បង្គន់ងាយស្រួល" ស្តង់ដារ។
*ក្រេឌីត៖ iDE Cambodia*



"បង្គន់កងលូ៖ ជម្រើសដែលកាន់តែសាមញ្ញ និងមានតម្លៃសមរម្យ។
*ក្រេឌីត៖ iDE Cambodia*

**ធ្វើការអង្កេតបណ្តើរៗ៖** អាកប្បកិរិយា ឥរិយាបថ ចំណេះដឹង និងការអនុវត្តដែលពាក់ព័ន្ធនឹងអនាម័យ មានលក្ខណៈផ្អែកតាមបរិបទបំផុត។ អាចធ្វើការស្រាវជ្រាវបណ្តើរៗដើម្បីស្វែងយល់កាន់តែច្បាស់ពីចំណុចទាំងនេះ និងរបៀបដែលចំណុចទាំងនេះប្រែប្រួលតាមក្រុមនានា ដើម្បីផ្តល់មូលដ្ឋានព័ត៌មានដល់ការដាក់បញ្ចូលយន្តការគាំទ្រចម្រុះ និងទទួលបានធាតុចូលពីអ្នកដែលអាចក្លាយជាអ្នកទទួលផល។ ឧ. សូមមើលការស្រាវជ្រាវរបស់ SNV ស្តីពីការប្រើប្រាស់បង្គន់ និងការលាងសម្អាតដៃជាមួយនឹងសាប៊ូ ដែលស្រាវជ្រាវពីភាពខុសគ្នាក្នុងចំណោមក្រុមជាតិពន្ធុ និងក្រុមសាសនានៅប្រទេសនេប៉ាល់ (SNV, 2015)។ ការជំរុញឱ្យរដ្ឋាភិបាលមូលដ្ឋានចូលរួមក្នុងការស្រាវជ្រាវនេះ អាចផ្តល់លទ្ធផលរៀនសូត្រផ្អែកតាមបទពិសោធន៍ដើម្បីជំរុញការប្តេជ្ញាចិត្តរបស់អ្នកដឹកនាំមូលដ្ឋានក្នុងការចូលដល់ជនគ្រប់រូប។



ការស្រាវជ្រាវបណ្តើរៗ ស្តីពីបទពិសោធន៍របស់ជនពិការក្នុងវិស័យទឹកស្អាត និងអនាម័យ។ ស្ត្រីគថ្លង់ម្នាក់ដែលមិនអាចនិយាយពី Sarlahi បានចែករំលែកបទពិសោធន៍ស្តីពីការប្រើប្រាស់ទឹក និងអនាម័យផ្ទាល់ខ្លួន (SNV ប្រទេសនេប៉ាល់)។
*ក្រេឌីត៖ Vijay Yadav, District DPO, Sarlahi ជំនួមុខឱ្យ SNV ប្រទេសនេប៉ាល់*

**តស៊ូមតិឱ្យប្រើប្រាស់វិធីសាស្ត្រផ្អែកតាមភស្តុតាង៖** អ្នកតាក់តែងគោលនយោបាយ និងអ្នកមានកាតព្វកិច្ចផ្សេងទៀត ដែលទទួលខុសត្រូវលើការធានាលទ្ធភាពទទួល បាន អនាម័យដោយសុវត្ថិភាព គួរផ្អែកលើភស្តុតាងមានស្រាប់ដើម្បីចូលដល់ជនគ្រប់រូប។ ទោះជាយ៉ាងណា ភស្តុតាងទាំងនេះច្រើនតែមានក្នុងឯកសារបោះពុម្ពផ្សាយដែលលំបាកបកប្រែ (ឧ. អត្ថបទទិន្នានុប្បវត្តិ និងរបាយការណ៍បច្ចេកទេសវែងអន្លាយ)។ ការតស៊ូមតិអនាម័យជនបទ គួរគាំទ្រដល់ការស្រាវជ្រាវក្នុងមូលដ្ឋានស្តីពីបញ្ហាប្រឈមរបស់គ្រួសារជួបការលំបាក និងជួយបកប្រែ និងបកស្រាយភស្តុតាងទាំងនោះទៅជាពាក្យពេចន៍ដែលអាចយល់បាន និងកសាងការយល់ដឹងស្តីពីមូលហេតុដែលវិធីសាស្ត្រផ្អែកតាមភស្តុតាងផ្តល់គុណប្រយោជន៍។

**លើកកម្ពស់បច្ចេកវិទ្យាអនាម័យបរិយាប័ន្ន៖** ជនពិការ ប្រហែលជាត្រូវការការរៀបចំផែនការ និងថវិកាជាក់លាក់ក្នុងអន្តរាគមន៍នានាដើម្បីបំពេញតម្រូវការរបស់ពួកគេ។ អ្នកអនុវត្តន៍ អ្នកដឹកនាំមូលដ្ឋាន និងអ្នកផ្សេងទៀត ប្រហែលជាត្រូវការការកសាងការយល់ដឹង និងការបណ្តុះបណ្តាលដែលគិតគូរពីជនពិការ ហើយប្រហែលជាត្រូវធ្វើការវាយតម្លៃបែបចូលរួមលើឧបសគ្គរាំងភាពងាយស្រួលប្រើប្រាស់។ មួយវិញទៀត ប្រហែលជាត្រូវបណ្តុះបណ្តាលជាងសំណង់ក្នុងមូលដ្ឋានដើម្បីឱ្យពួកគេអាចសង់បង្គន់ដែលគិតគូរពីជនពិការ។ ផ្នែកនេះត្រូវបានលើកមកពិភាក្សាលម្អិតក្នុងឯកសារទី ៣ នៃកម្រងឯកសារ "ព្រំដែននៃកម្មវិធីសហគមន៍ដឹកនាំអនាម័យទាំងស្រុង "ពិការភាព៖ ការធ្វើឱ្យកម្មវិធីសហគមន៍ដឹកនាំអនាម័យទាំងស្រុងមានលក្ខណៈបរិយាប័ន្នពេញលេញ"។



ការសង់បង្គន់សម្រាប់ជនពិការក្នុងទីក្រុង ដាកា ប្រទេសបង់ក្លាដេស។ *ក្រេឌីត ៖ Juliet Willetts*



ការត្រួតពិនិត្យភាពងាយស្រួលប្រើប្រាស់ ប្រទេសនីហ្សេរ។ *ក្រេឌីត៖ WEDC/Hazel Jones*

**ជំរុញការចូលរួមរបស់អង្គការតស៊ូមតិក្នុងមូលដ្ឋាន៖** ការជំរុញការចូលរួមរបស់អង្គការមូលដ្ឋាន ដែលមានបទពិសោធន៍លើការធ្វើការជាមួយ និងតស៊ូមតិគាំទ្រក្រុមជួបលំបាកជាក់លាក់ អាចជួយដល់ការកំណត់រកវិធីដែលមានប្រសិទ្ធភាព និងផ្តល់ការគោរព ដើម្បីធ្វើយ៉ាងណាឱ្យក្រុមជួបការលំបាកទទួលបានអត្ថប្រយោជន៍ ពីអន្តរាគមន៍អនាម័យជនបទ។ ឧ. អង្គការជនពិការនៅកម្ពុជា (DPO) នៅថ្នាក់ស្រុកបានជួយឱ្យមានការផ្តោតការយកចិត្តទុកដាក់លើក្រុមទាំងនេះ (ISF-UTS and SNV, 2018)។

## ជំហានទី ៤៖ ការពិនិត្យតាមដានលទ្ធផល

អ្នកអនុវត្តន៍ ឬអ្នកផ្តល់សេវា ត្រូវរៀបចំយុទ្ធសាស្ត្រសម្រាប់ពិនិត្យតាមដានលទ្ធផល ដើម្បីធានាការកាត់បន្ថយវិសមភាពដោយជោគជ័យ។ ក្នុងផ្នែកនេះ យើងពិភាក្សាពីបញ្ហាប្រឈមទូទៅ ធៀបនឹងកត្តាកំណត់ភាពជោគជ័យទាំង ៥ ដែលបានបង្ហាញពីខាងដើម និងវិធីនានាក្នុងការពិនិត្យតាមដានថាតើមានការសម្រេចបានភាពជោគជ័យ ឬទេ។

### លទ្ធផលទី ១៖ មនុស្សគ្រប់រូប រួមទាំងក្រុមជួបការលំបាក ទទួលបានហេដ្ឋារចនាសម្ព័ន្ធអនាម័យដែលសមស្រប និងអាចទទួលយកបាន

**បញ្ហាប្រឈម៖** ក្រុមជួបការលំបាក ប្រឈមនឹងហានិភ័យកាន់តែខ្ពស់នៃការមិនសម្រេចបានស្ថានភាពគ្មានការបន្ទោរបង់ពាសវាលពាសកាល ការសង់បង្គន់ដែលមិនពេញលក្ខខណ្ឌបច្ចេកទេស ឬការងាកទៅរកការបន្ទោរបង់ពាសវាលពាសកាល បន្ទាប់ពីការអនុវត្តកម្មវិធីអនាម័យជនបទ។ ដូច្នេះ ចាំបាច់ត្រូវពិនិត្យតាមដានថាតើកម្មវិធី ឬសេវាអនាម័យជនបទ អាចបំពេញតម្រូវការរបស់ក្រុមជួបការលំបាកបានគ្រប់គ្រាន់ ឬទេ។

**ការពិនិត្យតាមដាន៖** ត្រូវបែងចែកទិន្នន័យជាប្រភេទដើម្បីពិនិត្យថា មនុស្សគ្រប់រូប រួមទាំងក្រុមជួបការលំបាក កំពុងទទួលបានហេដ្ឋារចនាសម្ព័ន្ធអនាម័យ។ ចំណុចដៅទី១០ នៃគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពស្តីពីការកាត់បន្ថយវិសមភាព គូសបញ្ជាក់ពីការបែងចែកទិន្នន័យជាប្រភេទ ក្នុងសូចនាករទាំងអស់ នៃគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព ទៅតាម "ប្រាក់ចំណូល ភេទ អាយុ ជាតិសាសន៍ ជាតិពន្ធស្ថានភាពអន្តោប្រវេសន៍ ពិការភាព និងទីតាំងភូមិសាស្ត្រ ឬលក្ខណៈផ្សេងទៀត" (UNSD 2018 in Bain and Slaymaker 2018)។ ការបែងចែកទិន្នន័យជាប្រភេទ អាចបង្ហាញភាពខុសគ្នានៃអត្រា និងចំនួនសរុបរបស់ក្រុមផ្សេងទៀត ពាក់ព័ន្ធនឹងការទទួលបាន និងប្រើប្រាស់សេវាអនាម័យ។

**ខាងក្រោមនេះជាបញ្ហាប្រឈមក្នុងការបែងចែកទិន្នន័យជាប្រភេទ និងត្រូវដោះស្រាយ៖**

- **ចំណាយខ្ពស់លើការប្រមូលទិន្នន័យ៖** ការបែងចែកទិន្នន័យជាប្រភេទត្រូវចំណាយច្រើន ព្រោះច្រើនតែពាក់ព័ន្ធនឹងទំហំសំណាកគំរូធំ ឬការអង្កេតបន្ថែម ដើម្បីបង្ហាញភាពខុសគ្នារវាងក្រុមនានា (OHCHR 2012)។ ខណៈដែលការបែងចែកទិន្នន័យជាប្រភេទអាចចំណាយច្រើន មានការលើកឡើងថា វិស័យទឹកស្អាត និងអនាម័យត្រូវផ្តោតលើសពី "តម្លៃជាប្រាក់" និងកត់សម្គាល់ពីចំណាយលើការអភិវឌ្ឍមនុស្សដោយសារការផាត់ចេញនរណាម្នាក់ (Roaf et al. 2018)។
- **អាចបង្កើនការមាក់ងាយ៖** ការគូសបញ្ជាក់ពីភាពខុសគ្នារវាងក្រុមនានា អាចបង្កើនការមាក់ងាយចំពោះជនជួបការលំបាក (Wibur et al. 2018)។ ចាំបាច់ត្រូវអនុវត្តគោលការណ៍ "មិនបង្កគ្រោះថ្នាក់" និងជំហាននានាជាប់ជានិច្ចដើម្បីការពារភាពឯកជន និងការសម្ងាត់របស់សមាជិកសហគមន៍ ដែលចូលរួមក្នុងការប្រមូលទិន្នន័យ។

- ការបែងចែកជាក្រុមសង្គម៖ ការកំណត់អត្តសញ្ញាណជនជួបការលំបាកអាចមានការលំបាក ប្រសិនបើគ្មានការយល់ច្បាស់ពីលក្ខខណ្ឌ ឬក៏ជនជួបការលំបាកស្ទាក់ស្ទើរមិនហ៊ានឱ្យគេកំណត់អត្តសញ្ញាណ។ ឧ. ការបែងចែកជាប្រភេទអាចពាក់ព័ន្ធនឹងលក្ខណៈវិនិច្ឆ័យបែបបរានុម័ត ដូចជា ស្វ័យកំណត់អត្តសញ្ញាណជាមួយក្រុមសង្គមមួយ (OHCHR 2012)។ ក្នុងករណីមួយចំនួន គេអាចធ្វើការអង្កេតស្តង់ដារដែលមានការទទួលស្គាល់ជាអន្តរជាតិ ដើម្បីកំណត់ថានរណាម្នាក់ស្ថិតក្នុងក្រុមសង្គមណាមួយ (ឧ. សំណួររបស់ Washington Group សម្រាប់ជនពិការ) (Wilbur et al. 2018)។

**ករណីសិក្សាទី៣** (ទំព័រ....) បង្ហាញពីកម្មវិធីអនាម័យប្រកបដោយនិរន្តរភាពសម្រាប់មនុស្សគ្រប់រូប (SSH4A) របស់ SNV ក្នុងប្រទេសហ្សាំប៊ី និងតង់ហ្សានី។ កម្មវិធីនេះ (ដែលត្រូវបានអនុវត្តក្នុងប្រទេស ១៦ ទៀតនៅទូទាំងទ្វីបអាហ្វ្រិក និងអាស៊ី) ធ្វើការអង្កេតដែលស្ថិតក្រោមការរៀបចំ និងគ្រប់គ្រងដោយហ្មត់ចត់ ដើម្បីពិនិត្យតាមដានវឌ្ឍនភាពនៃលទ្ធភាពទទួលបាន ការប្រើប្រាស់ និងការជួសជុលថែទាំបង្គន់ សម្រាប់បញ្ហាភាគគ្រួសារស្តុកស្តម្ភនីមួយៗ និងគ្រួសារដែលមានស្ត្រីជាមេគ្រួសារ។

## លទ្ធផលទី ២៖ មនុស្សគ្រប់រូបប្រើប្រាស់ហេដ្ឋារចនាសម្ព័ន្ធអនាម័យជាប់លាប់

**បញ្ហាប្រឈម៖** ស្ថានភាពនៃការគ្មានការបន្ទោរបង់ពាសវាលពាសកាល ច្រើនតែត្រូវបានវាស់វែងធៀបនឹងថាតើមនុស្សគ្រប់រូបក្នុងសហគមន៍មួយមានបង្គន់អនាម័យ ឬទេ ប៉ុន្តែជាទូទៅ សមាជិកគ្រួសារមួយចំនួនប្រើប្រាស់បង្គន់មិនជាប់លាប់នោះទេ (Chambers and Myers 2016)។ ភាពក្រីក្រ អាយុ ពិការភាព និងយេនឌ័រ សុទ្ធតែអាចរួមចំណែកមួយផ្នែកដល់ការប្រើប្រាស់បង្គន់។ ឯកសារទី៧ នៃកម្រងឯកសារ "ព្រំដែននៃកម្មវិធីសហគមន៍ដឹកនាំអនាម័យទាំងស្រុង "បទដ្ឋានចំណេះដឹង និងការប្រើប្រាស់" ផ្តោតលម្អិតលើបញ្ហានេះ និងដំណោះស្រាយនានា។ ការពង្រឹងបរិយាកាស អំណោយផល ដើម្បីធានាអាកប្បកិរិយា និងការជួសជុលថែទាំល្អប្រសើរតាមបែបបច្ចេកទេស (ឧ. ការសម្អាតរណ្តៅបង្គន់) ជាប្រការសំខាន់ក្នុងការជំរុញការប្រើប្រាស់បង្គន់ជាប់លាប់ ដូចមានពិភាក្សាក្នុងឯកសារទី ៤ នៃកម្រងឯកសារ "ព្រំដែននៃកម្មវិធីសហគមន៍ដឹកនាំអនាម័យទាំងស្រុង៖ និរន្តរភាព និងសហគមន៍ដឹកនាំអនាម័យទាំងស្រុង៖ ការគិតគូរពិចារណា" (Cavill et al. 2015)។



បង្គន់រណ្តៅដែលពេញប្រៀប ភូមិ Syedpur ប្រទេសបង់ក្លាដេស។ *ក្រេឌីត ៖ Suzanne Hanchett*

**ការពិនិត្យតាមដាន៖** ការប្រើប្រាស់បង្គន់ច្រើនតែត្រូវបានពិនិត្យដោយផ្អែកតាមការរាយការណ៍ដោយខ្លួនឯងក្នុងការអង្កេត ឬសៀវភៅកំណត់ហេតុរបស់អ្នកប្រើប្រាស់ ទោះបីជា ការស្រាវជ្រាវបង្ហាញពីការលើកឡើងច្រើនជ្រុលពីការប្រើប្រាស់ មធ្យោបាយនេះក្តី (Sinha et al. 2016)។ ប្រសិនបើគេប្រើប្រាស់ការរាយការណ៍ដោយខ្លួនឯងដើម្បីពិនិត្យតាមដានការប្រើប្រាស់បង្គន់ ការសួរសមាជិកគ្រួសារម្នាក់ៗថាតើពួកគេបានប្រើប្រាស់បង្គន់ក្នុងរយៈពេល ៤៨ ម៉ោងកន្លងមក ឬទេ (និងការបែងចែកតាមថ្ងៃជាពេលព្រឹក រសៀល ល្ងាច និងយប់) អាចផ្តល់លទ្ធផលត្រឹមត្រូវ ជាងការសួរក្រុមសមាជិកគ្រួសារពីចំនួនដងដែលពួកគេតែងប្រើប្រាស់ ឬចំនួនដងជាមធ្យមក្នុងមួយថ្ងៃ (Sinha et al.2016)។ គួររក្សាតុល្យភាពសំណួរ (ឧ. "តើអ្នកបន្ទោរបង់កណ្តាលវាល ឬក្នុងបង្គន់?" ជាជាងសួរថា "តើអ្នកប្រើបង្គន់ ឬទេ?") (Coffey and Spears 2014)។ របាយការណ៍ផ្ទាល់ខ្លួនទាំងនេះអាចយកទៅប្រៀបធៀបនឹងការសង្កេតមើលស្ថានភាពបង្គន់ (ឧ. ដើម្បីពិនិត្យថាតើបង្គន់ដែលគេនិយាយថាមានការប្រើប្រាស់ ជាបង្គន់ដែលអាចប្រើប្រាស់បាននិងដំណើរការ ឬថាតើត្រូវបូមលាមកចេញពីរណ្តៅ ឬទេ)។ ទិន្នន័យទាំងនេះគួរត្រូវបានបែងចែកជាប្រភេទតាមដែលអាចធ្វើទៅបាន ដើម្បីស្វែងយល់ថាតើក្រុមមួយចំនួនកំពុងប្រើប្រាស់បង្គន់មិនសូវញឹកញាប់ជាងក្រុមផ្សេងទៀត ឬទេ។ ដូច្នេះ ចាំបាច់ត្រូវបញ្ជ្រាបដំណើរការពិនិត្យតាមដាន និងយន្តការពាក់ព័ន្ធសម្រាប់ការលើកឡើងពីការភ្លាំងភ្លាត់ និងវិសមភាពក្នុងស្ថាប័នរបស់អ្នកផ្តល់សេវា ឬរចនាសម្ព័ន្ធអាជ្ញាធរផ្តល់សេវា ដើម្បីធានាការប្រើប្រាស់បង្គន់ជាប់លាប់។

## លទ្ធផលទី ៣៖ យន្តការគាំទ្រត្រូវបានបញ្ជ្រាបក្នុងស្ថាប័នរបស់រដ្ឋាភិបាល វិស័យឯកជន និងដំណើរការរបស់វិស័យផ្សេងទៀត



អាជីវកម្មអនាម័យ ផលិតបង្គន់ដែលមានតម្លៃទាបក្នុងប្រទេសឥណ្ឌូនេស៊ីភាគខាងកើត។ *ក្រេឌីត៖ Janina Murta*

**បញ្ហាប្រឈម៖** ស្ថាប័នអាជ្ញាធរមូលដ្ឋានច្រើនតែមានភារកិច្ចធានាការផ្តល់សេវាអនាម័យ ប៉ុន្តែ ប្រហែលជាមានមិនសូវមានធនធានហិរញ្ញវត្ថុ អំណាចធ្វើសេចក្តីសម្រេច និងសមត្ថភាពធនធានមនុស្ស ក្នុងការអនុវត្តយន្តការគាំទ្រនោះទេ ហើយវិស័យឯកជនប្រហែលជាយល់ថា ការផ្តោត អាទិភាពលើតម្រូវការរបស់ក្រុមជួបការលំបាក គ្មានប្រសិទ្ធភាពចំណាយ។ ការតស៊ូមតិឱ្យមានការពិចារណាកាន់តែដិតដល់ ពីសមភាពអនាម័យក្នុងការរៀបចំថវិកា និងផែនការរបស់រដ្ឋាភិបាល និងការអភិវឌ្ឍគំរូអាជីវកម្មដែលគាំទ្រ ជនក្រីក្រ នឹងអាចជួយ ដោះស្រាយបញ្ហាទាំងនេះបាន។ ក្រៅពីនេះ អាចមានអំពើពុករលួយ ក្នុងករណីមានការផ្តល់

ជំនួយហិរញ្ញវត្ថុ។ ដូច្នេះត្រូវបង្កើត និងអនុវត្តយន្តការគណនេយ្យភាពដោយប្រុងប្រយ័ត្ន។

**ការពិនិត្យតាមដាន៖** គួរពិនិត្យឡើងវិញលើឯកសាររបស់រដ្ឋាភិបាល ឬធ្វើបទសម្ភាសន៍ជាមួយអាជ្ញាធររដ្ឋាភិបាល និងអ្នកផ្តល់ព័ត៌មានសំខាន់ផ្សេងទៀត ដើម្បីកំណត់ពីកម្រិតដែលដំណើរការរបស់រដ្ឋាភិបាលត្រូវបានបង្កើតឡើង សម្រាប់លើកឡើងពីសមភាពអនាម័យ។ ឧ. ក្នុងករណីសិក្សាទី ២ (ទំព័រ...) វិធីសាស្ត្រផ្អែកតាមដំណាក់កាលសម្រាប់កម្មវិធីអនាម័យទាំងស្រុង (PhATS) ពិនិត្យថាតើមានការបង្កើតថវិកាមូលដ្ឋានសម្រាប់អង្គភាពរដ្ឋាភិបាលមូលដ្ឋាន ឬទេ។ វិស័យឯកជនអាចធ្វើការវាយតម្លៃដើមគ្រាតាមរយៈបទសម្ភាសន៍ជាមួយម្ចាស់អាជីវកម្ម ដើម្បីស្វែងយល់ពីកម្រិតដែលពួកគេផ្តោតលើការចូលដល់ក្រុមជួបការលំបាក ហើយការពិនិត្យលម្អិតលើអ្នកដែលពិតជាបានចូលដល់តាមរយៈអាជីវកម្មទាំងនេះ ប្រហែលជាត្រូវមានកិច្ចសហប្រតិបត្តិការយ៉ាងជិតស្និទ្ធ និងការពង្រីកដំណើរការមានស្រាប់សម្រាប់ការតាមដានអតិថិជនរបស់ពួកគេ។

**លទ្ធផលទី ៩៖ យន្តការឧបត្ថម្ភថវិកា ឬសម្ភារៈ ដើម្បីបង្កើនលទ្ធភាពទទួលបានអនាម័យក្នុងតំបន់មួយ មិនសុទ្ធតែរាំងស្ទះដល់វឌ្ឍនភាពក្នុងតំបន់ផ្សេងទៀត ឬទីផ្សារទឹកស្អាតនិងអនាម័យឡើយ**

**បញ្ហាប្រឈម៖** ប្រសិនបើយន្តការគាំទ្រ ជាពិសេសយន្តការដែលរួមបញ្ចូលការឧបត្ថម្ភថវិកា ត្រូវបានយកទៅអនុវត្តក្នុងសហគមន៍មួយ សហគមន៍ផ្សេងទៀតអាចនឹងបានដឹងរួចពន្យារពេលសង់បង្គន់ដោយរំពឹងថា ពួកគេអាចនឹងទទួលបានការឧបត្ថម្ភថវិកា ឬសម្ភារៈដែរ (Crocker et al., 2016)។ ក្រៅពីនេះ អ្នកដែលដឹង ឬមិនដឹងថាគ្មានលក្ខណៈសម្បត្តិទទួលបានការឧបត្ថម្ភ អាចដាក់ពាក្យសុំជំនួយ។ ការបង្ហាញច្បាស់ពីគោលបំណង និងដំណើរការសម្រាប់ការផ្តល់យន្តការគាំទ្រ អាចជួយគ្រប់គ្រងក្តីរំពឹងទុកបាន។ ការឧបត្ថម្ភថវិកា និងសម្ភារៈ អាចធ្វើឱ្យប៉ះពាល់ដល់ទីផ្សារក្នុងមូលដ្ឋាន ព្រោះវាធ្វើឱ្យអ្នកផ្គត់ផ្គង់ផ្សេងទៀតមិនអាចចូលរួមក្នុងអន្តរាគមន៍នេះបាន។ វិធីមួយក្នុងការកាត់បន្ថយផលប៉ះពាល់នេះគឺការផ្តល់ជំនួយដល់អ្នកផ្គត់ផ្គង់ទាំងអស់ក្នុងតំបន់មួយ ដែលបំពេញលក្ខណៈវិនិច្ឆ័យនៃលក្ខណៈសម្បត្តិជាក់លាក់ (ឧ. លក្ខណៈវិនិច្ឆ័យអាចតម្រូវឱ្យអ្នកផ្គត់ផ្គង់ឆ្លងកាត់វគ្គបណ្តុះបណ្តាលស្តីពីការផ្តល់ទំនិញ និងសេវាដែលមានសុវត្ថិភាព ដែលរៀបចំឡើងដោយរដ្ឋាភិបាល ឬអង្គការមិនមែនរដ្ឋាភិបាលមួយ) (Dwan and Bond 2016)។

**ការពិនិត្យតាមដាន៖** វិធីមួយក្នុងការពិនិត្យតាមដានថាតើឥរិយាបថក្នុងសហគមន៍ផ្សេងទៀតរងផលប៉ះពាល់ ឬទេ គឺត្រូវជំរុញការចូលរួមរបស់រដ្ឋាភិបាលមូលដ្ឋាន។ ឧ. ក្នុងការពិនិត្យឡើងវិញលើការឧបត្ថម្ភគាំទ្រជនក្រីក្រដោយ SNV សម្រាប់អនាម័យជនបទនៅកម្ពុជា មានការសម្ភាសន៍អាជ្ញាធររដ្ឋាភិបាលថ្នាក់ឃុំ និងភូមិ។ ដំណើរការនេះបង្ហាញថាការលើកទឹកចិត្តគ្រួសារដែលមិនមែនជាក្រុមគោលដៅ មិនបង្កផលប៉ះពាល់អវិជ្ជមាននោះទេ និងមានការយល់ដឹងយ៉ាងច្បាស់ថា យន្តការនេះផ្តោត លើគ្រួសារក្រីក្របំផុត (Murta et al. 2017)។ ទោះជាយ៉ាងណា បញ្ហានេះអាចកើតឡើង ព្រោះប្រព័ន្ធអត្តសញ្ញាណកម្មគ្រួសារក្រីក្ររបស់រដ្ឋាភិបាលកម្ពុជា ត្រូវបានគេស្គាល់ច្បាស់ និងទទួល

យកជាប្រព័ន្ធសម្រាប់ការវាយតម្លៃ និងការធ្វើអត្តសញ្ញាណកម្មភាពក្រីក្រ។ ប្រទេសជាច្រើនផ្សេងទៀតគ្មានប្រព័ន្ធសម្រាប់ការវាយតម្លៃ ឬការធ្វើអត្តសញ្ញាណកម្មដែលត្រូវបានគេស្គាល់ និងទទួលយកដូចប្រព័ន្ធរបស់កម្ពុជាទេ។ ប្រព័ន្ធដ៏ល្អសម្រាប់ការផ្ទៀងផ្ទាត់ការទាមទារលក្ខណៈសម្បត្តិដោយផ្អែកលើការពិនិត្យតាមដានទិន្នន័យ (ឧ. សូមមើលករណីសិក្សាទី ១ ទំព័រ....) អាចជួយកាត់បន្ថយកំហុសឆ្គងពាក់ព័ន្ធនឹងការរួមបញ្ចូល។ តម្លៃដែលនៅថេរ (ទោះបីជាតម្លៃសម្ភារៈកើនឡើង) អាចបង្ហាញថាទីផ្សារនេះទទួលរងផលប៉ះពាល់។ បទសម្ភាសន៍បែបគុណភាពជាមួយអ្នកផ្គត់ផ្គង់ ដែលមិនពាក់ព័ន្ធក្នុងអន្តរាគមន៍នេះ ឬបទសម្ភាសន៍ជាមួយអ្នកផ្តល់ព័ត៌មានសំខាន់ផ្សេងទៀត (ឧ.សមាគមអាជីវកម្មនៅមូលដ្ឋាន) អាចបង្ហាញថាតើយន្តការនេះបង្កផលប៉ះពាល់ដោយផ្ទាល់លើឆន្ទៈបង់ថវិកា ឬទេ)។

## លទ្ធផលទី ៥៖ ចំណាយលើយន្តការគាំទ្រ មិនមែនជាកត្តារាំងស្ទះដល់ការពង្រីកយន្តការនេះឡើយ

**បញ្ហាប្រឈម៖** ការបន្ថែមយន្តការគាំទ្រអាចបង្កើនចំណាយ និងភាពស្មុគស្មាញនៃការរៀបចំកម្មវិធីអនាម័យ និងការផ្តល់សេវា។ យន្តការគាំទ្រមួយចំនួនអាចមានប្រសិទ្ធភាពក្នុងការផ្តល់លទ្ធផលដែលមានសមធម៌ក្នុងមូលដ្ឋាន ប៉ុន្តែលំបាកពង្រីកដោយសារតែកម្មវិធីត្រូវចំណាយច្រើនពេក ឬគ្មានរចនាសម្ព័ន្ធគ្រប់គ្រង និងរដ្ឋបាលចាំបាច់នៅកម្រិតតំបន់ ឬជាតិ។ យន្តការមួយចំនួន អាចទាមទារសមត្ថភាពធនធានមនុស្សយ៉ាងច្រើន (ឧ. អ្នកសម្របសម្រួលដែលមានជំនាញ) ដែលមិនអាចរកបាន។ សំខាន់បំផុតត្រូវពិចារណាពីអត្ថប្រយោជន៍រយៈពេលវែង នៅពេលពិនិត្យមើលប្រសិទ្ធភាពចំណាយ ព្រោះផលចំណេញផ្នែកសេដ្ឋកិច្ចពីការវិនិយោគអនាម័យ អាចស្តែងចេញក្នុងរយៈពេលយូរ និងនៅពេលដែលមនុស្សគ្រប់រូបក្នុងតំបន់មួយប្រើប្រាស់បង្គន់អនាម័យ។

**ការពិនិត្យតាមដាន៖** ការប្រមូលទិន្នន័យស្តីពីចំណាយក្នុងមួយគ្រួសារ (ឬក្នុងមនុស្សម្នាក់) របស់យន្តការគាំទ្រមួយ ជួយកំណត់ថាតើគេអាចពង្រីកយន្តការនេះបាន ឬទេ។ ចំណាយដែលគួរតាមដាន រួមមាន ចំណាយពាក់ព័ន្ធនឹងយន្តការគាំទ្រផ្ទាល់ (ឧ. តម្លៃនៃឧបត្ថម្ភធនឬសម្ភារៈឬបច្ចេកវិទ្យាដែលផ្តល់ជូន)ពេលវេលានិងកម្លាំងពលកម្មសម្រាប់ការផ្តល់យន្តការនេះ (ឧ. សម្រាប់ការបណ្តុះបណ្តាលអ្នកសម្របសម្រួលថ្មី ឬការធ្វើដំណើរទៅទីតាំងអន្តរាគមន៍) និងការពិនិត្យតាមដាន និងការផ្ទៀងផ្ទាត់ បន្ថែមលើប្រភេទចំណាយតាមកម្មវិធីស្តង់ដារ (សូមមើល WaterAid, Plan International and UNICEF 2018)។ ក្រៅពីនេះ គេអាចសិក្សាពីចំណាយនៅថ្នាក់តំបន់ ឬជាតិ ដើម្បីកំណត់ថាតើយន្តការនេះអាចពង្រីកបាន ឬទេ។

### តើអ្នកអាចកំណត់បានដោយរបៀបណាថា យន្តការគាំទ្រមួយដំណើរការ?

តើអ្នកអាចកំណត់បានដោយរបៀបណាថា យន្តការគាំទ្រមួយដំណើរការ? ការបង្កើតមធ្យោបាយសម្រាប់កំណត់ថាតើយន្តការគាំទ្រមួយ "ដំណើរការ" ឬយ៉ាងណា អាស្រ័យលើលក្ខណៈរបស់យន្តការនោះ និងបរិបទមូលដ្ឋាន។ គេច្រើនធ្វើការសាកល្បងគ្រប់គ្រងដោយចៃដន្យព្រោះវាបានផ្តល់ទម្រង់ភស្តុតាងល្អិតល្អន់បំផុត ប៉ុន្តែមធ្យោបាយនេះអាចលំបាកអនុវត្ត និងចំណាយច្រើន មិនផ្តល់ចំណេះដឹង បែបគុណភាពស្តីពីរបៀប ឬមូលហេតុដែលយន្តការនានាដំណើរការ និងអាចប្រឈមនឹងបញ្ហាក្រមសីលធម៌ធ្ងន់ធ្ងរ នៅពេលផ្តោតលើក្រុមជួបការលំបាក។ ជារួមភាពជាដៃគូរឹងមាំរវាងអ្នកអនុវត្តន៍ និងអ្នកស្រាវជ្រាវក្នុងការរៀបចំការសិក្សាសម្រាប់ករណីជាក់លាក់ នឹងជួយដោះស្រាយបញ្ហាប្រឈមផ្នែកបរិបទ និងបង្កើតភស្តុតាងដោយផ្អែកលើប្រសិទ្ធភាពរបស់យន្តការទាំងនោះ (Venkataramanan et al. 2018)។

## ជំហានទី ៥៖ ការចែករំលែកចំណេះដឹង ការរៀនសូត្រ និងការកែសម្រួល

ទិន្នន័យមិនអាចជួយកាត់បន្ថយវិសមភាពបានឡើយ។ មុននឹងអនុវត្តកម្មវិធីមួយ ត្រូវរៀបចំថវិកា និងផែនការជាស្រេចដើម្បីសម្រេចពីរបៀបវិភាគទិន្នន័យ និងអ្នកដែលត្រូវពាក់ព័ន្ធក្នុងការបកស្រាយការវិភាគ ពន្យល់ពីរបៀបឆ្លុះបញ្ចាំងលទ្ធផលរកឃើញ និងកំណត់ពេលដែលអាចកែសម្រួលការរៀបចំកម្មវិធីទៅតាមបរិបទ ដោយផ្អែកលើអ្វីដែលត្រូវបានរៀនសូត្រ។ មុននឹងអនុវត្ត ការរៀបចំកម្មវិធី គួរត្រូវបានកែសម្រួលឱ្យស៊ីសង្វាក់គ្នានឹងការកំណត់បឋមពីផលប៉ះពាល់ដែលជោគជ័យ និងលទ្ធផលនៃអនាម័យជនបទដែលមានសមធម៌ ទៅតាមការព្រមព្រៀង (និងល្អបំផុត ត្រូវបន្សុីគ្នានឹងចំណុចដៅទី ៦.២ នៃគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព)។

ព័ត៌មានដែលប្រមូលបានពីដំណើរការពិនិត្យតាមដាន នឹងជួយកសាងមូលដ្ឋានភស្តុតាងសម្រាប់ការប្រើប្រាស់ក្នុងវិស័យទឹកស្អាត និងអនាម័យដើម្បីរៀបចំ និងអនុវត្តអន្តរាគមន៍អនាម័យដែលកាន់តែមានប្រសិទ្ធភាព និងសមធម៌។ អ្នកដឹកនាំគួររៀបចំពេលវេលា ទីតាំង និងធនធានសម្រាប់ការចែករំលែកចំណេះដឹង និងការរៀនសូត្រ។ ការស្រាវជ្រាវលើកឡើងថា ក្នុងចំណោមអង្គការសង្គមស៊ីវិលដែលធ្វើការក្នុងវិស័យទឹកស្អាត និងអនាម័យ ការរៀនសូត្រផ្ទាល់ជាមួយអ្នកដែលមានវ័យ និងបទពិសោធន៍ស្របាលគ្នាពិតជាចាំបាច់ណាស់ ហើយរបាយការណ៍ផ្តល់ប្រយោជន៍ច្រើនបំផុតនៅពេលវាមានភាពជាក់ស្តែង ខ្លីងាយយល់ និងផ្អែកតាមភស្តុតាង។ ក្រៅពីនេះ មគ្គុទេសក៍ស្តីពី "របៀបធ្វើ" ក៏ចាំបាច់ផងដែរ ប៉ុន្តែប្រហែលជាត្រូវមានការណែនាំលើការយកទៅអនុវត្ត (Grant et al. 2016)។

## ការកំណត់ពេលវេលា ៖ ពេលដែលត្រូវអនុវត្តយន្តការគាំទ្រ?

ពេលវេលាដែលគួរផ្តល់យន្តការគាំទ្រដល់អន្តរាគមន៍អនាម័យជនបទ គឺជាចំណុចដ៏សំខាន់។ មានភស្តុតាងតិចតួចស្តីពីការកំណត់ពេលវេលាសមស្រប ប៉ុន្តែពេលវេលាដែលមានប្រសិទ្ធភាពបំផុតក្នុងការអនុវត្តយន្តការគាំទ្រ អាស្រ័យលើ ១) លក្ខណៈរបស់យន្តការគាំទ្រ និង ២) បរិបទជាក់លាក់។

ផ្នែកទី ១ នៃឯកសារនេះគូសបញ្ជាក់ថា វិសមភាពក្នុងគ្រួសារ និងអន្តរគ្រួសារគួរត្រូវបានលើកមកពិចារណាមុន បន្ទាប់ពី និងក្នុងអំឡុងដំណាក់កាលទាំងអស់នៃកម្មវិធីអនាម័យ (House et al. 2017)។ មិនច្បាស់ថាតើ ការអភិវឌ្ឍការដឹកនាំក្នុងមូលដ្ឋានសម្រាប់ការកៀរគរសកម្មភាពរួម ការតស៊ូមតិផ្អែកតាមភស្តុតាងដើម្បីគាំទ្រក្រុមជួបការលំបាក និងការលើកកម្ពស់បច្ចេកវិទ្យាអនាម័យបរិយាប័ន្ន នឹងផ្តល់គុណប្រយោជន៍គ្រប់ពេល ឬយ៉ាងណានោះទេ។

ទោះជាយ៉ាងណា ត្រូវផ្តួចផ្តើមយន្តការគាំទ្រជាច្រើនតាំងពីដំបូងក្នុងអន្តរាគមន៍មួយ។ ការដាក់បញ្ចូលយន្តការនានាក្នុងគោលការណ៍ណែនាំ យុទ្ធសាស្ត្រ កម្មវិធី និងថវិការបស់រដ្ឋាភិបាលអាចមានភាពយឺតយ៉ាវ និងត្រូវពិចារណាជិតដល់មុននឹងចាប់ផ្តើមកម្មវិធីអនាម័យជនបទ។ កម្មវិធីត្រូវធ្វើការស្រាវជ្រាវបណ្តើរៗតាំងពីដំបូង ដើម្បីផ្តល់មូលដ្ឋានព័ត៌មានដល់សកម្មភាពអនុវត្តន៍។ ការជំរុញឱ្យមានការបង្កើតគំរូអាជីវកម្មដែលគាំទ្រជនក្រីក្រ អាចទាមទារពេលវេលាយ៉ាងច្រើន។ ដូច្នេះ កម្មវិធីអនាម័យត្រូវចាប់ផ្តើមអនុវត្តគំរូទាំងនោះតាំងពីដំបូង។

សម្រាប់ការឧបត្ថម្ភថវិកា ឬសម្ភារៈដល់អ្នកប្រើប្រាស់ មានទាំងគុណសម្បត្តិ និងគុណវិបត្តិពាក់ព័ន្ធនឹងការផ្តល់ ឬការផ្សព្វផ្សាយពីការឧបត្ថម្ភនេះដល់អ្នកប្រើប្រាស់តាំងពីពេលដំបូង ឬនៅពេលបន្ទាប់ក្នុងកម្មវិធី។

**តារាង ២៖** គុណសម្បត្តិ និងគុណវិបត្តិនៃការកំណត់ពេលវេលាផ្តល់ការឧបត្ថម្ភថវិកា និងសម្ភារៈ

| | **គុណសម្បត្តិ** | **គុណវិបត្តិ** |
|---|---|---|
| ការឧបត្ថម្ភធ្វើឡើងនៅកៀកពេលចាប់ផ្តើមអន្តរាគមន៍ (ឧ. សូមមើលការបង្វិលថវិកាសងវិញជាមុនក្នុងករណីសិក្សាទី ១ ទំព័រ....) | • ជួយជំរុញឱ្យគ្រួសារគោលដៅប្រមូលផ្តុំភ្លាមៗ<br>• ផ្តល់លទ្ធភាពដល់ការដឹកជញ្ជូនសម្ភារៈ/ផលិតផលទាំងដុលពីអ្នកផ្គត់ផ្គង់ | • អាចរាំងស្ទះដល់ការផ្លាស់ប្តូរឥរិយាបថ និងដំណោះស្រាយក្នុងមូលដ្ឋាន<br>• អាចប៉ះពាល់ដល់ទីផ្សារនៅមូលដ្ឋាន |

| | | |
|---|---|---|
| ការឧបត្ថម្ភធ្វើឡើងតែនៅក្រោយពេលសម្រេចបានកម្រិតជាក់លាក់នៃស្ថានភាពគ្មានការបន្ទោរបង់ពាសវាលពាសកាល ឬបន្ទាប់ពីសម្រេចបានសកម្មភាព ឬលទ្ធផលផ្សេងទៀត (ឧ. សូមមើលការផ្តល់រង្វាន់ដល់សហគមន៍ក្នុងករណីសិក្សាទី ២ ទំព័រ....) | • ជំរុញតម្រូវការអនាម័យ និងពង្រឹងការផ្លាស់ប្តូរឥរិយាបថ<br>• សម្របសម្រួលដល់ការចូលរួមជាប្រចាំជាមួយសហគមន៍ក្រោយគ្មានការបន្ទោរបង់ពាសវាលពាសកាល។ | • គ្រួសារក្រីក្រអាចយល់ថារងភាពអាម៉ាស់ និងធ្វើការសម្រេចចិត្តអវិជ្ជមាន (ឧ. ការលក់ទ្រព្យសម្បត្តិដើម្បីយកប្រាក់ទៅសង់បង្គន់) (House et al. 2017)<br>• អាចពន្យារពេលសម្រេចបានស្ថានភាពគ្មានការបន្ទោរបង់ពាសវាលពាសកាលរបស់ក្រុមជួបការលំបាក។ |

ប្រភព ៖ ដកស្រង់ចេញពី WASHPaLS 2018 and Willetts 2013

ចាំបាច់ត្រូវបង្កើតមូលដ្ឋានភស្តុតាង ស្តីពីការកំណត់ពេលផ្តល់ការឧបត្ថម្ភ។ អ្នកអនុវត្តន៍គួរខិតខំចងក្រងឯកសារស្តីពីបទពិសោធន៍ ភាពជោគជ័យ និងបញ្ហាប្រឈមក្នុងការកំណត់ពេលវេលាជាក់លាក់ និងពិភាក្សាពីកត្តាតាមបរិបទដែលអាចជះឥទ្ធិពលលើចំណុចទាំងនេះ។ ប្រសិនបើអាច គួរប្រៀបធៀបការកំណត់ពេលវេលាផ្សេងៗក្នុងកម្មវិធីមួយ (ដូចជាតាមរយៈការសាកល្បងគ្រប់គ្រងដោយចៃដន្យ)។ ការចែករំលែកលទ្ធផលរកឃើញជាមួយវិស័យទឹកស្អាត និងអនាម័យ នឹងផ្តល់បទពិសោធន៍យ៉ាងច្រើនសម្រាប់ការរៀបចំការណែនាំដោយផ្អែកតាមព័ត៌មានត្រឹមត្រូវ សម្រាប់អ្នកអនុវត្តន៍ និងអ្នកផ្តល់សេវា។

ខាងក្រោមនេះ ជាសំណួរសំខាន់ៗមួយចំនួន ដើម្បីជួយដល់ការកំណត់ពេលវេលាដែលត្រូវផ្សព្វផ្សាយ និងផ្តល់ការឧបត្ថម្ភថវិកា និងសម្ភារៈដល់អ្នកប្រើប្រាស់ ក្នុងសហគមន៍ និងថាតើគួរផ្តល់ការឧបត្ថម្ភថវិកា ឬយ៉ាងណា៖

- តើទិន្នន័យដែលមាន បង្ហាញពីកម្រិតខ្ពស់នៃភាពក្រីក្រដែលអាចរឹតត្បិតសមត្ថភាពរបស់គ្រួសារក្នុងការសង់បង្គន់ដែលមានគុណភាព ឬទេ?
- តើមានគោលនយោបាយរដ្ឋាភិបាល ស្តីពីការកំណត់ពេលវេលាសម្រាប់ការឧបត្ថម្ភថវិកា ឬនិងសម្ភារៈ ឬទេ? តើមានបទពិសោធន៍អ្វីខ្លះក្នុងមូលដ្ឋានពាក់ព័ន្ធនឹងការឧបត្ថម្ភទាំងនេះ?
- តើសហគមន៍ធ្លាប់បានទទួលការឧបត្ថម្ភ ឬទេ ឬក៏សហគមន៍ជិតខាងធ្លាប់បានទទួលការឧបត្ថម្ភ?
- តើមានសម្ភារៈក្នុងមូលដ្ឋានសម្រាប់ឱ្យគ្រួសារសង់បង្គន់ដែលមានគុណភាពល្អឬទេ ឬក៏ពួកគេត្រូវការជំនួយដើម្បីទទួលបានសម្ភារទាំងនេះ?

## ករណីសិក្សាស្តីពីការអនុវត្តយន្តការគាំទ្រ

ករណីសិក្សា ៣ ក្នុងប្រទេសវៀតណាម ហ្វីលីពីន ហ្សាំប៊ី និងតង់ហ្សានី មានបង្ហាញក្នុងផ្នែកខាងក្រោម។ ករណីសិក្សានីមួយៗរៀបរាប់ពីអន្តរាគមន៍ដែលប្រើប្រាស់កម្រងយន្តការគាំទ្រផ្សេងៗ ដើម្បីចូលដល់ក្រុមជួបការលំបាក ក៏ដូចជាភាពជោគជ័យ និងបញ្ហាប្រឈម។

### ករណីសិក្សាទី ១៖ ការផ្តល់ជំនួយអនាម័យដល់សហគមន៍ដោយផ្អែកលើលទ្ធផល (CHOBA) ក្នុងប្រទេសវៀតណាម

**អ្នកអនុវត្តន៍៖** មូលនិធិ East Meets West (EMB) (ផ្តល់មូលនិធិដោយមូលនិធិ Bill and Melinda Gates)

**គោលដៅ៖** គ្របដណ្តប់លើប្រជាជនក្រីក្រ ១២៥.០០០ គ្រួសារក្នុងឃុំ ២៤៦ នៃខេត្ត ៨ ក្នុងតំបន់ជនបទនៅប្រទេសវៀតណាម (២០១២-២០១៦)។

**ទិដ្ឋភាពរួមនៃកម្មវិធី៖** កម្មវិធី CHOBA ត្រូវបានបង្កើតឡើងដោយមូលនិធិ EMW ដោយអនុវត្តវិធីសាស្ត្រផ្អែកលើលទ្ធផល (OBA) ដើម្បីឱ្យគ្រួសារនានា ជាពិសេសគ្រួសារជនបទក្រីក្រមានបង្គន់អនាម័យ។ សកម្មភាពបំផុសដែលស្រដៀងគ្នានឹងសហគមន៍ដឹកនាំអនាម័យទាំងស្រុង ត្រូវបានយកមកអនុវត្តដើម្បីបំផុសការស្អប់ខ្ពើមការបន្ទោរបង់ពាសវាលពាសកាល់ និងលើកកម្ពស់ឥរិយាបថអនាម័យល្អ។ គ្រួសារក្រីក្រមានលក្ខណៈសម្បត្តិទទួលបានប្រាក់កម្ចីតាមរយៈរដ្ឋាភិបាលមូលដ្ឋាន ហើយអ្នកដែលទិញសម្ភារៈសង់បង្គន់ទទួលបានការបង្វិលប្រាក់ជូនវិញចំនួន ២៨ដុល្លារ។ ចំណាយក្នុងកម្មវិធីនេះគឺប្រហែល ៥០ ដុល្លារ/គ្រួសារ។ មូលនិធិ EMW បានផ្តល់ការផ្ទេរថវិកាដោយមានលក្ខខណ្ឌដល់ឃុំដែលសម្រេចបានកំណើនវិសាលភាពអនាម័យ៣០ % ធៀបនឹងចំណុចដៅគោល និងការផ្ទេរថវិកាដោយមានលក្ខខណ្ឌ មួយផ្សេងទៀត ប្រសិនបើ ពួកគេសម្រេចបានវិសាលភាព អនាម័យ ៩៥%។ កម្មវិធីនេះ បានគាំទ្រដល់ការបណ្តុះបណ្តាលជាងសំណង់ក្នុងមូលដ្ឋានស្តីពីការសង់បង្គន់ និងជំរុញឱ្យសហជីពស្ត្រីវៀតណាម (VWU) ចូលរួមលើកកម្ពស់ ការមានបង្គន់ប្រើប្រាស់ និងអនាម័យ



គ្រួសារក្នុងកម្មវិធី CHOBA ដែលរស់នៅក្នុងខេត្តត្រាវិញ ប្រទេសវៀតណាម។ *រក្សាសិទ្ធ៖ Morgan Ommer*

ល្អ ជួយដល់គ្រួសារក្រីក្រក្នុងការទទួលបានកម្ចី និងសម្របសម្រួលការបណ្តុះបណ្តាលជាងសំណង់ក្នុងមូលដ្ឋាន។ ក្រៅពីនេះ មានការចូលរួមរបស់គណៈកម្មាធិការប្រជាជនឃុំ (ស្ថាប័នរដ្ឋាភិបាលមូលដ្ឋាន) លើការផ្តល់ការគាំទ្រផ្នែកនយោបាយ និងរដ្ឋបាល។ សហជីពស្ត្រីវៀតណាម និងគណៈកម្មាធិការប្រជាជនឃុំទទួលបានប្រាក់លើកទឹកចិត្តទៅតាមចំនួនគ្រួសារក្រីក្រ ដែលបានសង់បង្គន់។

**យន្តការគាំទ្រដែលបានប្រើប្រាស់រួមមានៈ**

- ការបង្វិលថវិកាសងជូនគ្រួសារក្រីក្រ
- រដ្ឋាភិបាលចាត់ចែងផ្តល់កម្ចីដល់គ្រួសារដែលបានសង់បង្គន់
- ការផ្ទេរប្រាក់ដោយមានលក្ខខណ្ឌដល់ឃុំ
- ការផ្តល់ប្រាក់លើកទឹកចិត្តដល់ដៃគូអនុវត្តន៍ និងរដ្ឋាភិបាលមូលដ្ឋាន
- ការបណ្តុះបណ្តាលជាងសំណង់នៅមូលដ្ឋានស្តីពីការសង់បង្គន់
- ការជំរុញការចូលរួមរបស់ស្ថាប័នរដ្ឋាភិបាលមូលដ្ឋាន
- ការលើកកម្ពស់អនាម័យល្អ និងការប្រើប្រាស់បង្គន់។

**ក្រុមគោលដៅក្នុងយន្តការគាំទ្រៈ** ប្រជាជនក្រីក្របំផុតចំនួន ៤០% នៃចំនួនប្រជាជនសរុប។ គ្រួសារដែលមានវិញ្ញាបនបត្រក្រីក្រចេញដោយរដ្ឋាភិបាល ត្រូវបានបែងចែកជាប្រភេទ "ជិតក្រីក្រ" ក្នុងកំណត់ត្រារដ្ឋាភិបាល ឬកំពុងប្រឈមនឹង "ការលំបាកផ្នែកសេដ្ឋកិច្ច" យោងតាមលក្ខណៈវិនិច្ឆ័យទ្រព្យសម្បត្តិ និងប្រាក់ចំណូលដែលបង្កើតឡើងដោយមូលនិធិ EMW មានលក្ខណៈសម្បត្តិទទួលបានការឧបត្ថម្ភសម្រាប់ការសង់បង្គន់។

**លទ្ធផលសម្រាប់ការរួមបញ្ចូលៈ** បង្គន់ចំនួន ១១៣.៥០០ ត្រូវបានសង់ដោយក្រុមប្រជាជនគោលដៅ (ប្រជាជនក្រីក្របំផុតចំនួន ៤០% នៃចំនួនប្រជាជនសរុប)។ ទោះជាយ៉ាងណាភាគច្រើននៃបង្គន់ទាំងនេះ ត្រូវបានសង់ដោយប្រភេទគ្រួសារ ដែលប្រឈមនឹង "ការលំបាកផ្នែកសេដ្ឋកិច្ច" ដោយយោងតាមលក្ខណៈវិនិច្ឆ័យរបស់មូលនិធិ EMW។ ក្នុងនោះ គ្រួសារក្រីក្រ ភាគច្រើនមិនសូវក្រីក្រដូចគ្រួសារដែលមានវិញ្ញាបនបត្រក្រីក្រ ឬត្រូវបានកំណត់ជាប្រភេទ "ជិតក្រីក្រ" ដោយយោងតាមកម្រិតប្រាក់ចំណូលដែលកំណត់ដោយរដ្ឋាភិបាល។ ថ្នាក់ដឹកនាំឃុំជាច្រើនយល់ថា កម្រិតវិសាលភាពអនាម័យ ៩៥% សម្រាប់ការទទួលបានការផ្ទេរប្រាក់ដោយមានលក្ខខណ្ឌ គឺមិនងាយសម្រេចបានទេ ហើយគ្រួសារក្រីក្រប្រហែលជាមិនព្យាយាមសម្រេចបានកម្រិតនេះឡើយ។ ដូច្នេះ មូលនិធិ EMW បានកែសម្រួលកម្រិតនេះមកត្រឹម ៧៥% ប៉ុន្តែមានឃុំតែ ១៦ ប៉ុណ្ណោះដែលសម្រេចបានកម្រិតនេះ ខណៈដែលកម្មវិធីមានគោលដៅសម្រេចបាន ៧១ ឃុំ។

**ការពិនិត្យតាមដាន និងវាយតម្លៃៈ** មូលនិធិ EMW បានបង្កើតមូលដ្ឋានទិន្នន័យដែលមានព័ត៌មានដើមគ្រាដែលបានប្រមូលជាមួយគណៈកម្មាធិការប្រជាជនឃុំ និងមេភូមិស្តីពីលទ្ធភាពទទួលបានអនាម័យតាមគ្រួសារ និងលក្ខណៈសម្បត្តិសម្រាប់ការទទួល

បានការឧបត្ថម្ភក្នុងតំបន់កម្មវិធី។ គ្រួសារ និងសហគមន៍ដែលទាមទារការបង្វិលប្រាក់សង ឬការផ្ទេរប្រាក់ដោយមានលក្ខខណ្ឌ ត្រូវបានផ្ទៀងផ្ទាត់តាមរយៈការពិនិត្យបង្គន់ផ្ទាល់ដោយសហជីពស្ត្រីវៀតណាម ឬបុគ្គលិករបស់មូលនិធិ EMW និងការពិនិត្យផ្ទៀងផ្ទាត់ជាមួយទិន្នន័យដើមគ្រាដើម្បីបញ្ជាក់ថា អ្នកទាមទារមានលក្ខណៈសម្បត្តិទទួលបានការឧបត្ថម្ភ។ មូលនិធិ EMW បានអនុវត្តការសាកល្បងគ្រប់គ្រងដោយចៃដន្យ និងរកឃើញថា ការបង្វិលប្រាក់សងវិញក្នុងOBA ធ្វើឱ្យមានការប្រើប្រាស់បង្គន់យ៉ាងច្រើន ហើយ ការបង្វិលប្រាក់សងនេះ មានប្រសិទ្ធភាពជាងការផ្ទេរប្រាក់ដោយមានលក្ខខណ្ឌដល់ឃុំ។

## ការឆ្លុះបញ្ចាំង/មេរៀនសំខាន់ៗ៖

- ការបង្វិលប្រាក់សងវិញក្នុង OBA ជាយន្តការដែលមានប្រសិទ្ធភាពសម្រាប់ការបង្កើនការសង់បង្គន់ដោយគ្រួសារក្រីក្រ ជាងការផ្ទេរប្រាក់ ដោយមានលក្ខខណ្ឌ ឬអន្តរាគមន៍ទីផ្សារអនាម័យដាច់ដោយឡែកមួយ។
- កម្មវិធី CHOBA មានប្រសិទ្ធភាពនៅពេលចូលដល់គ្រួសារដែលប្រឈមនឹងការលំបាក ប៉ុន្តែមិនបានចូលដល់គ្រួសារក្រីក្រទាំងអស់នោះទេ។ ចំណុចនេះអាចដោយសារតែទំហំប្រាក់បង្វិលសងវិញមិនគ្រប់គ្រាន់ សម្រាប់ឱ្យគ្រួសារក្រីក្របំផុតសង់បង្គន់ និងដោយសារតែគ្រួសារក្រីក្របំផុតប្រឈមនឹងឧបសគ្គក្នុងការទទួលបានប្រភពឥណទានផ្លូវការ និងក្រៅផ្លូវការ។
- ការបង្កើតមូលដ្ឋានទិន្នន័យពិនិត្យតាមដាន និងវាយតម្លៃគ្រប់ជ្រុងជ្រោយ និងល្អិតល្អន់ គឺជាកត្តាកំណត់ភាពជោគជ័យនៃកម្មវិធី CHOBA និងជាសមាសភាគដ៏សំខាន់មួយក្នុងវិធីសាស្ត្រ OBA។
- មានការសម្របសម្រួល រវាងការធានាបានអត្រាខ្ពស់នៃការរាយការណ៍ពីសុក្រឹតភាពក្នុងការផ្ទៀងផ្ទាត់ និងការចំណាយ។ ឧ. ការបណ្តុះបណ្តាលអ្នកអនុវត្តន៍ក្នុងមូលដ្ឋានសម្រាប់ការពិនិត្យតាមដាន និងវាយតម្លៃសកម្មភាពនានាដែលអាចទុកចិត្តបាន និងត្រឹមត្រូវ ត្រូវចំណាយពេលយូរ។
- ការស្រាវជ្រាវគ្រប់ជ្រុងជ្រោយនឹងបង្ហាញពី ផលប៉ះពាល់នៃយន្តការគាំទ្រក្នុងកម្មវិធី CHOBA ប៉ុន្តែមានបញ្ហាប្រឈមក្នុងការអនុវត្តការសិក្សានេះ។ ដៃគូរដ្ឋាភិបាលក្នុងមូលដ្ឋានជំទាស់មិនផ្តល់ការគាំទ្រ ផ្នែករដ្ឋបាលលើការសាកល្បងគ្រប់គ្រងដោយចៃដន្យ ដោយសារតែភាពស្មុគស្មាញក្នុងការអនុវត្ត។ ក្រៅពីនេះ រដ្ឋាភិបាលមូលដ្ឋាន និងដៃគូអនុវត្តន៍ក្នុងការសាកល្បងគ្រប់គ្រង ជំទាស់នឹងការណ៍ដែលគ្រួសារក្រីក្រក្នុងតំបន់របស់ខ្លួនមិនទទួលបានការឧបត្ថម្ភ។

ប្រភពព័ត៌មាន៖ EMW 2016; Nguyen et al. 2013; Larsen and Connell 2015; Reviewed by Hanh Nguyen (EMW)

## ករណីសិក្សាទី ២៖ កម្មវិធីស្តារអនាម័យទាំងស្រុងឡើងវិញដោយប្រើប្រាស់វិធីសាស្ត្រផ្អែកតាមដំណាក់កាលនៃព្យុះហៃយ៉ាន

### អ្នកផ្តល់ជំនួយមូលនិធិ និងអ្នកសម្របសម្រួល៖ UNICEF

**គោលដៅ៖** គ្របដណ្តប់លើអ្នកទទួលផល ៩០០.០០០ នាក់ក្នុងក្រុង ៤០ និងខេត្ត ៦ ក្នុងប្រទេសហ្វីលីពីន ដែលរងផលប៉ះពាល់ដោយសារ "ព្យុះកំណាចហៃយ៉ាន" (២០១៤-២០១៦)។



ម្តាយ និងកូនឈរនៅជិតបង្គន់សង់ថ្មីនៅតំបន់ដែលរងការវាយប្រហារដោយព្យុះហៃយ៉ាន, UNICEF ហ្វីលីពីន ២០១៤។
*ក្រេឌីត ៖ Joey Reyna*

ទិដ្ឋភាពរួមនៃកម្មវិធី៖ កម្មវិធីស្តារអនាម័យទាំងស្រុងឡើងវិញដោយប្រើប្រាស់ វិធីសាស្ត្រផ្អែកតាមដំណាក់កាលនៃព្យុះហៃយ៉ាន (PhATS) មានគោលបំណងលុបបំបាត់ ការបន្ទោរបង់ ពាសវាលពាសកាល និងធ្វើឱ្យសហគមន៍ ឈានទៅទទួលបានសេវាអនាម័យកាន់តែខ្ពស់ ក្រោយគ្រោះមហន្តរាយ "ព្យុះកំណាចហៃយ៉ាន" ក្នុងប្រទេសហ្វីលីពីន។ កម្មវិធីនេះត្រូវបានអនុវត្តដោយ សម្ព័ន្ធអង្គការមិនមែនរដ្ឋាភិបាល ១២ និងសមភាគីរដ្ឋាភិបាល។ កម្មវិធី PhATS បានញែកការវិវឌ្ឍនៃអនាម័យជាដំណាក់កាលខាងក្រោម ប៉ុន្តែអ្នកអនុវត្តន៍នីមួយៗមានវិធីសាស្ត្រជាក់លាក់រៀងៗខ្លួន៖

- កម្រិត "គ្មានការបន្ទោរបង់ពាសវាលពាសកាល" (ZOD)[2]៖ ដើម្បីសម្រេចបានកម្រិតនេះ គ្រួសារ១០០%ក្នុងសហគមន៍មួយត្រូវប្រើប្រាស់បង្គន់អនាម័យ ដោយមានសាប៊ូ និងទឹកនៅជិតបង្គន់។ ដៃគូអនុវត្តន៍ (រួមមានអង្គការមិនមែនរដ្ឋាភិបាលចម្រុះ និងសមភាគីរដ្ឋាភិបាលមូលដ្ឋាន) បានប្រើប្រាស់គំនិតផ្តួចផ្តើមសហគមន៍ដឹកនាំអនាម័យទាំងស្រុង ទីផ្សារអនាម័យ និងយុទ្ធនាការបណ្តាញផ្សព្វផ្សាយ ដើម្បីបង្កើនតម្រូវការអនាម័យ (អ្នកអនុវត្តន៍ខ្លះយល់ថា គំនិតផ្តួចផ្តើមសហគមន៍ដឹកនាំអនាម័យទាំងស្រុង គឺមិនសមស្របក្នុងបរិបទក្រោយគ្រោះអាសន្នឡើយ)។ ក្នុងបរិបទក្រោយគ្រោះអាសន្ន អ្នកអនុវត្តន៍មួយចំនួនបានផ្តល់ការឧបត្ថម្ភ ជាសម្ភារៈ និងប័ណ្ណទូទាត់ (ដែលមានតម្លៃប្រហែល ១៣៥ ដុល្លារ ប៉ុន្តែទឹកប្រាក់នេះប្រែប្រួលទៅតាមអ្នកអនុវត្តន៍) ដល់គ្រួសារក្រីក្រ និងងាយរងគ្រោះដើម្បី

[2]គ្មានការបន្ទោរបង់ពាសវាលពាសកាលក្នុងប្រទេសហ្វីលីពីន សំដៅលើតំបន់ដែលគ្មានការបន្ទោរបង់ពាសវាលពាសកាល ១០០%។

ជួយដល់ការសង់បង្គន់ (ក្រោមស្ថានភាពមិនមែនគ្រោះអាសន្ន គ្មានការផ្តល់ជំនួយហិរញ្ញវត្ថុទេលុះត្រាតែសម្រេចបានស្ថានភាព គ្មានការបន្ទោរបង់ពាសវាលពាសកាល)។

- កម្រិត "អនាម័យដែលមាននិរន្តរភាព"៖ អ្នកអនុវត្តន៍ផ្តល់ប្រាក់លើកទឹកចិត្តដល់សហគមន៍ ដែលសម្រេចបានកម្រិតគ្មានការបន្ទោរបង់ពាសវាលពាសកាលចំនួន ៥០០ ដុល្លារ (ផ្តល់ដោយ UNICEF) ដើម្បីបន្តអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធអនាម័យដែលកាន់តែមានអនាម័យ និងនិរន្តរភាព។ ចំណុចនេះរួមមានការរចនាអាងស្តុកលាមក ដែលអាចបូមសម្អាតដោយសុវត្ថិភាព បង្គន់ដែលទប់ស្កាត់មិនឱ្យលាមកមនុស្ស ប៉ះពាល់ដល់មនុស្ស និងបង្គន់ដែលបញ្ចេញក្លិនអាក្រក់តិចតួច។ល។ ដៃគូអនុវត្តន៍បានរៀបចំការបណ្តុះបណ្តាលជាងសំណង់ និងគាំទ្រឱ្យអាជីវកម្មមូលដ្ឋានបង្កើតសង្វាក់ផ្គត់ផ្គង់អនាម័យ។ សហគមន៍នឹងសម្រេចបានកម្រិតអនាម័យ ដែលមាននិរន្តរភាពនៅពេលគ្រួសារ ១០០% ប្រើប្រាស់បង្គន់ផ្ទាល់ខ្លួនដែលបានកែលម្អដោយមានកន្លែងលាងសម្អាតដៃហើយស្ថាប័ន ១០០% ក្នុងសហគមន៍មានបង្គន់ដែលបានកែលម្អ។
- កម្រិត "អនាម័យទាំងស្រុង"៖ សហគមន៍ដែលសម្រេចបានកម្រិត "អនាម័យដែលមាននិរន្តរភាព" ទទួលបានទឹកប្រាក់ ៦០០ ដុល្លារបន្ថែមទៀតពីអ្នកអនុវត្តន៍ដើម្បីឈានទៅសម្រេចបានកម្រិត "អនាម័យទាំងស្រុង" ។ ការបំពេញលក្ខខណ្ឌអនាម័យទាំងស្រុង រួមមាន ការសម្រេចបានលក្ខខណ្ឌទាំងអស់ពីកម្រិតមុនៗបូករួមនឹងការគ្រប់គ្រងសំណល់រឹង និងរាវ និងការកែលម្អកន្លែងលាងសម្អាតដៃ ដែលកាត់បន្ថយការធ្វើឱ្យកខ្វក់ឡើងវិញដោយសារដៃកខ្វក់។ អ្នកអនុវត្តន៍បានជួយដល់អង្គភាពរដ្ឋាភិបាលមូលដ្ឋានក្នុងការរៀបចំផែនការទឹកស្អាត និងអនាម័យដោយផ្អែកតាមហានិភ័យគ្រោះមហន្តរាយ និងបង្កើតថវិកាផ្ទាល់ខ្លួនសម្រាប់ការកែលម្អអនាម័យ។

**យន្តការគាំទ្រដែលបានប្រើប្រាស់រួមមាន៖**

- ការឧបត្ថម្ភជាសម្ភារៈ និងប័ណ្ណទូទាត់ដល់គ្រួសារក្រីក្រ និងងាយរងគ្រោះសម្រាប់ការសង់បង្គន់ (ក្នុងស្ថានភាពគ្រោះអាសន្ន)។
- ការផ្តល់ប្រាក់លើកទឹកចិត្តដល់សហគមន៍ឱ្យប្រើប្រាស់សេវាអនាម័យដែលមានការកែលម្អ
- ការផ្តល់ជំនួយដល់អាជីវកម្មមូលដ្ឋានឱ្យបង្កើតសង្វាក់ផ្គត់ផ្គង់អនាម័យ
- ការបណ្តុះបណ្តាលជាងសំណង់ក្នុងមូលដ្ឋានពីការសង់បង្គន់
- ការជំរុញស្ថាប័នរដ្ឋាភិបាលមូលដ្ឋាន ឱ្យចូលរួមក្នុងការធ្វើផែនការ អនុវត្ត និងពិនិត្យតាមដានកម្មវិធី
- ការរៀបចំផែនការទឹកស្អាត និងអនាម័យ និងថវិកាអនាម័យក្នុងអង្គភាពរដ្ឋាភិបាលមូលដ្ឋាន

- ការលើកកម្ពស់អនាម័យ និងការបង្កើតតម្រូវការ។

**ក្រុមគោលដៅក្នុងយន្តការគាំទ្រ៖** ដៃគូអនុវត្តន៍នីមួយៗ មានលក្ខណៈវិនិច្ឆ័យ និង ដំណើរការផ្ទៀងផ្ទាត់រៀងៗខ្លួន សម្រាប់ការកំណត់អត្តសញ្ញាណអ្នកទទួលផលដែលត្រូវទទួលបានការឧបត្ថម្ភសម្រាប់ការសង់បង្គន់។ លក្ខណៈវិនិច្ឆ័យរួមមាន អ្នកដែលមានកម្រិតប្រាក់ចំណូលទាបជាងកម្រិតដែលបានកំណត់ ឬគ្មានសមាជិកគ្រួសារណាម្នាក់មានការងារជាប់លាប់ គ្រួសារដែលមានស្ត្រីជាមេគ្រួសារ មានសមាជិកគ្រួសារណាម្នាក់ពិការ និងសមាជិកគ្រួសារណាម្នាក់មានផ្ទៃពោះ។ អ្នកអនុវត្តន៍មួយចំនួនប្រើប្រាស់កម្មវិធីមានស្រាប់នៅថ្នាក់ជាតិ (កម្មវិធីផ្ទេរប្រាក់ដោយមានលក្ខខណ្ឌ ឬ 4Ps) ដើម្បីកំណត់អត្តសញ្ញាណគ្រួសារជួបការលំបាក។

**លទ្ធផលសម្រាប់ការរួមបញ្ចូល៖** សមាមាត្រគ្រួសារក្នុងតំបន់កម្មវិធី PhATS ដែលប្រើប្រាស់ហេដ្ឋារចនាសម្ព័ន្ធអនាម័យ ដែលបានកែលម្អ និងមិនប្រើប្រាស់រួម កើនឡើងពីចំនួន ៦៥% រហូតដល់ចំនួន ៧៦%។ សមាមាត្រគ្រួសារដែលបន្ទោរបង់ពាសវាលពាសកាល មិនប្រែប្រួលច្រើននោះទេ។ ប៉ុន្តែគួរកត់សម្គាល់ថា កម្មវិធី PhATS អនុវត្តដំណាក់កាលឆ្លើយតបនឹងគ្រោះមហន្តរាយធ្ងន់ធ្ងរ ដែលរួមបញ្ចូលការលើកកម្ពស់អនាម័យ និងការផ្តល់ហេដ្ឋារចនាសម្ព័ន្ធអនាម័យរួម ឬសម្ភារភាព។ សហគមន៍ចំនួន ៩៣៧ ត្រូវបានបញ្ជាក់ថាសម្រេចបានកម្រិតគ្មានការបន្ទោរបង់ពាសវាលពាសកាល ហើយសហគមន៍ចំនួន ២៨៨ ត្រូវបានបញ្ជាក់ថាសម្រេចបានកម្រិត "អនាម័យដែលមាននិរន្តរភាព" ។ ក្រុមដែលស្ថិតក្រោមការគ្រប់គ្រង មិនត្រូវបានប្រើប្រាស់ក្នុងពេលវាយតម្លៃទេ និងគ្មានការបែងចែកទិន្នន័យជាប្រភេទសម្រាប់ក្រុមក្រីក្រ និងក្រុមងាយរងគ្រោះឡើយ។

**ការពិនិត្យតាមដាន និងវាយតម្លៃ៖** នាយកដ្ឋានសុខាភិបាលថ្នាក់តំបន់ បានដឹកនាំការរៀបចំគោលការណ៍ណែនាំស្តីពីការផ្ទៀងផ្ទាត់ ការផ្តល់វិញ្ញាបនបត្រ និងការពិនិត្យតាមដានកម្រិតនីមួយៗ ហើយ ដៃគូអនុវត្តន៍ទាំងអស់ត្រូវអនុវត្តតាម។ ចំណុចនេះរួមមានការផ្ទៀងផ្ទាត់ស្ថានភាពគ្មានការបន្ទោរបង់ពាសវាលពាសកាល (ផ្អែកលើគោលការណ៍ណែនាំថ្នាក់ជាតិ) និងលក្ខខណ្ឌផ្សេងទៀតសម្រាប់ការសម្រេចបានកម្រិតនីមួយៗ ដោយក្រុមផ្ទៀងផ្ទាត់ថ្នាក់ក្រុង (ដែលមានសមាសភាគអ្នកផ្ទៀងផ្ទាត់តតីយជនម្នាក់) និងការផ្តល់វិញ្ញាបនបត្រដោយក្រុមថ្នាក់ខេត្ត។ ដៃគូអនុវត្តន៍ទាំងអស់បានលើកឡើងធៀបនឹងសូចនាករគោល ដែលរួមមានការប្រើប្រាស់អនាម័យគ្រប់គ្រាន់ ការមានកន្លែងលាងសម្អាតដៃនៅផ្ទះ អង្គភាពរដ្ឋាភិបាលមូលដ្ឋានដែលមានថវិកាអនាម័យដែលបានអនុម័ត និងចំនួនប្រជាជនដែលរស់នៅក្នុងសហគមន៍គ្មានការបន្ទោរបង់ពាសវាលពាសកាលដែលត្រូវបានបញ្ជាក់។

**ការឆ្លុះបញ្ចាំង/មេរៀនសំខាន់ៗ៖**

- ការខូចខាតយ៉ាងធ្ងន់ធ្ងរដោយសារព្យុះហៃយ៉ាន ធ្វើឱ្យមានតម្រូវការកម្លាំង

ពលកម្មជំនាញ និងសម្ភារៈសាងសង់យ៉ាងច្រើន។ បញ្ហានេះ បូករួមនឹងការឧបត្ថម្ភយ៉ាងច្រើនលើហេដ្ឋារចនាសម្ព័ន្ធទឹកស្អាត និងអនាម័យពីសំណាក់អង្គការមិនមែនរដ្ឋាភិបាលផ្សេងទៀត បានធ្វើឱ្យគ្រួសារស្ទាក់ស្ទើរមិនចង់វិនិយោគលើការសង់បង្គន់។ ត្រូវមានកិច្ចខិតខំប្រឹងប្រែងយ៉ាងច្រើនក្នុងការបញ្ចុះបញ្ចូលឱ្យទីភ្នាក់ងារមនុស្សធម៌ ឈប់ប្រើប្រាស់វិធីសាស្ត្រផ្តល់ការឧបត្ថម្ភយ៉ាងច្រើន។

- ការបែងចែករង្វាន់ ឬគ្រឿងលើកទឹកចិត្តដល់សហគមន៍ គួរសមាមាត្រទៅតាមចំនួនគ្រួសារដែលត្រូវការជំនួយដើម្បីសម្រេចបានលទ្ធផលជាសមូភាព។
- នៅពេលអនុវត្តវិធីសាស្ត្រផ្តល់ការឧបត្ថម្ភ ប្រការសំខាន់ត្រូវបញ្ចៀសភាពលម្អៀងដែលអាចកើតឡើង។ ក្នុងបរិបទនេះ អ្នកដែលអាចក្លាយអ្នកទទួលផលពីការឧបត្ថម្ភបង្គន់ គួរត្រូវបានកំណត់អត្តសញ្ញាណដោយក្រុមប្រឹក្សាមូលដ្ឋាន ដោយពិគ្រោះយោបល់ជាមួយសហគមន៍ មិនមែនធ្វើឡើងដោយមន្ត្រីដែលបានចាត់តាំងនោះទេ។
- ការអនុញ្ញាតឱ្យសហគមន៍សម្រេចចិត្ត និងចាត់វិធានការលើបញ្ហាប្រឈម ឬឧបសគ្គនានាក្នុងពេលអនុវត្តន៍គម្រោតង នឹងបង្កើនសិទ្ធិអំណាច និងពង្រឹងស្មារតីទទួលខុសត្រូវរបស់ពួកគេ។
- គួរបន្តផ្តោតអាទិភាពលើការពង្រឹងបរិយាកាសអំណោយផល ក្នុងវិស័យទឹកស្អាត និងអនាម័យ សូម្បីតែក្នុងបរិបទក្រោយគ្រោះអាសន្ន។មានផលប៉ះពាល់វិជ្ជមាន លើកម្រិតនៃការបញ្ជ្រាបកម្មវិធីតាមស្ថាប័នទៅក្នុងអាទិភាពគោលនយោបាយ ផែនការ និងថវិការបស់រដ្ឋាភិបាលមូលដ្ឋានក្នុងករណីរួមបញ្ចូលការតស៊ូមតិជាមួយអ្នកដឹកនាំនៅមូលដ្ឋានតាំងពីដំបូង។
- យុទ្ធសាស្ត្រច្បាស់លាស់មួយសម្រាប់ការបង្កើតតម្រូវការ ក្រោយការសម្រេចបានស្ថានភាពគ្មានការបន្ទោរបង់ពាសវាលពាសកាល ពិតជាចាំបាច់ណាស់ក្នុងការធានាការពង្រឹងសារសំខាន់ៗ ស្តីពីការគ្មានការបន្ទោរបង់ពាសវាលពាសកាល និងការលាងសម្អាតដៃនៅពេលវេលាសំខាន់ៗ។
- ការវិនិយោគរបស់រដ្ឋាភិបាលមូលដ្ឋានលើអនាម័យ កើនឡើងនៅពេលមានការរំពឹងថា សហគមន៍នឹងឈានពីការបន្ទោរបង់ពាសវាលពាសកាល ឆ្ពោះទៅរកសេវាកម្រិតខ្ពស់។

*ប្រភពព័ត៌មាន ៖ Robinson and Gnilo, 2016; UNICEF, 2016; Reviewed by Louise Maule (UNICEF Philippines) and Andy Robinson (ទីប្រឹក្សាឯករាជ្យ)។*

## ករណីសិក្សាទី ៣៖ អនាម័យដែលមាននិរន្តរភាពសម្រាប់មនុស្សគ្រប់រូប (SSH4A) ក្នុងប្រទេសហ្សាំប៊ី និងតង់ហ្សានី

**អ្នកអនុវត្តន៍៖** SNV ( ផ្តល់មូលនិធិដោយ DFID)

**គោលដៅ៖** ផ្តោតលើស្រុក ៤ ក្នុងខេត្តភាគខាងជើងនៃប្រទេសហ្សាំប៊ី និងស្រុក ៥ ក្នុងតំបន់បឹង និងតំបន់ភាគខាងជើងក្នុងប្រទេសតង់ហ្សានី (២០១៤-២០១៧)។

**ទិដ្ឋភាពរួមនៃកម្មវិធី៖** កម្មវិធី SSH4A ផ្តោតលើលទ្ធផលអនាម័យទូទាំងស្រុកនិងការជំរុញការចូលរួមរយៈពេលវែង ដើម្បីធានានិរន្តរភាពនៃការផ្លាស់ប្តូរឥរិយាបថអនាម័យ។ កម្មវិធីនេះអនុវត្តក្របខណ្ឌមួយដែលមានសមាសភាគបំពេញឱ្យគ្នា ៤៖ ការបង្កើតតម្រូវការអនាម័យ សង្វាក់ផ្គត់ផ្គង់អនាម័យ និងហិរញ្ញវត្ថុ ការផ្លាស់ប្តូរឥរិយាបថអនាម័យតាមរយៈការប្រាស្រ័យទាក់ទង និងអភិបាលកិច្ចទឹកស្អាត និងអនាម័យ។ សកម្មភាពនានាត្រូវបានគាំទ្រដោយកម្រងសកម្មភាពរៀនសូត្រ និងការពិនិត្យតាមដានការអនុវត្ត និងផ្អែកតាមបទពិសោធន៍អនុវត្តន៍កម្មវិធី SSH4A ជិតមួយទសវត្សរ៍ក្នុងបណ្តាប្រទេសផ្សេងទៀត។ មានសកម្មភាពជាច្រើនក្នុងប្រទេសហ្សាំប៊ី ៖

- បុគ្គលឆ្នើមក្នុងសហគមន៍ ណែនាំគ្រួសារស្តីពីបង្គន់ដែលបំពេញស្តង់ដាររដ្ឋាភិបាលក្នុងវគ្គបំផុសសហគមន៍ដឹកនាំអនាម័យទាំងស្រុង។
- ក្រុមទីផ្សារអនាម័យ ត្រូវបានបង្កើតឡើងដើម្បីកៀរគរធនធានហិរញ្ញវត្ថុនៅថ្នាក់ភូមិសម្រាប់ទិញសម្ភារសង់បង្គន់ (ទិញដុំ) និងទទួលបានការបញ្ចុះតម្លៃសម្រាប់ក្រុមក្រីក្រ។
- សារផ្លាស់ប្តូរឥរិយាបថត្រូវបានកែសម្រួលតាមរយៈការស្រាវជ្រាវបណ្តើរៗ និងផ្អែកតាមក្រុមគោលដៅជាក់លាក់(ឧ.បញ្ជាភាគគ្រួសារក្រីក្របំផុតគ្រួសារដែលមានស្ត្រីជាមេគ្រួសារ)។

ប្រទេសតង់ហ្សានីក៏មានសកម្មភាពជាច្រើនផងដែរ ៖

- អ្នកដឹកនាំក្នុងមូលដ្ឋាន ទទួលបានជំនួយក្នុងការផ្តល់សារផ្លាស់ប្តូរឥរិយាបថអនាម័យ ដែលកែសម្រួលទៅតាមក្រុមគោលដៅជាក់លាក់ (ឧ. គ្រួសារដែលមានស្ត្រីជាមេគ្រួសារ គ្រួសារដែលមានសមាជិកជាជនពិការ)
- ម្ចាស់អាជីវកម្មក្នុងមូលដ្ឋាន ត្រូវបានគាំទ្រក្នុងការធ្វើទីផ្សារ និងសង់បង្គន់ដែលជាប់ធន់ និងចំណាយតិច និងកែលម្អទៅជាបង្គន់មូលដ្ឋាន។
- មានការចែកកូនសៀវភៅព័ត៌មានដល់គ្រួសារ ដើម្បីឱ្យពួកគេអាចសម្រេចចិត្តដោយផ្អែកតាមព័ត៌មានត្រឹមត្រូវ ស្តីពីការរចនាអនាម័យបែបបរិយាប័ន្នសម្រាប់ជនពិការ។

**ក្រុមគោលដៅក្នុងយន្តការគាំទ្រ៖** កម្មវិធីថ្នាក់ប្រទេសទាំងក្នុងប្រទេសហ្សាំប៊ី និងតង់ហ្សានី សុទ្ធតែផ្តោតលើបណ្តាស្រុកដែលមានអត្រាវិសាលភាពអនាម័យទាបនិង

ទទួលបានការគាំទ្រតិចតួចក្នុងយុទ្ធនាការអនាម័យថ្នាក់ជាតិកន្លងមក។ ក្នុងស្រុកពាក់ព័ន្ធ បញ្ហាភាគគ្រួសារក្រីក្របំផុត គ្រួសារដែលមានស្រ្តីជាមេគ្រួសារ និងជនពិការត្រូវបានកំណត់អត្តសញ្ញាណថាងាយរងគ្រោះ តាមរយៈការសិក្សាស្រាវជ្រាវបណ្តើរៗ។

**លទ្ធផលសម្រាប់ការរួមបញ្ចូល៖** ក្នុងប្រទេសហ្សាំប៊ី ការបន្ទោរបង់ពាសវាលពាសកាលក្នុងបណ្តាស្រុកនានា ថយចុះពីចំនួន ៥០% មកត្រឹម ៥%។ សម្រាប់បញ្ហាភាគគ្រួសារក្រីក្រ ការបន្ទោរបង់ពាសវាលពាសកាលថយចុះពីចំនួន ៩១% មកត្រឹម ១១%។ សម្រាប់គ្រួសារដែលមានស្រ្តីជាមេគ្រួសារ ការបន្ទោរបង់ពាសវាលពាសកាលបានថយចុះពីចំនួន ៥៧% មកត្រឹម ៧%។ សមាមាត្រប្រជាជនដែលប្រើប្រាស់ និងមានបង្គន់ឯកជនដែលស្អាត និងដំណើរការ កើនពីចំនួន ៧% ដល់ ៧០% សម្រាប់គ្រួសារទាំងអស់, កើនពីចំនួន ១% ដល់ ៥៦% សម្រាប់បញ្ហាភាគគ្រួសារក្រីក្របំផុត កើនពីចំនួន ៦% ដល់ ៦៨% សម្រាប់គ្រួសារដែលមានស្រ្តីជាមេគ្រួសារ និងកើនពីចំនួន ៧% ដល់ ៦៦% សម្រាប់គ្រួសារដែលមានសមាជិកជាជនពិការ។ ក្នុងប្រទេសតង់ហ្សានី ការបន្ទោរបង់ពាសវាលពាសកាលថយចុះពីចំនួន ៣៦% មកត្រឹម ២% សម្រាប់គ្រួសារទាំងអស់, ថយចុះពីចំនួន ៧៦% មកត្រឹម ៩% សម្រាប់បញ្ហាភាគគ្រួសារក្រីក្របំផុត ថយចុះពីចំនួន ៩០% មកត្រឹម ៣% សម្រាប់គ្រួសារដែលមានស្រ្តីជាមេគ្រួសារ និងថយចុះពីចំនួន ៣៩% មកត្រឹម ៣% សម្រាប់គ្រួសារដែលមានសមាជិកជាជនពិការ។ សមាមាត្រប្រជាជនដែលប្រើប្រាស់ និងមានបង្គន់ឯកជនដែលស្អាត និងដំណើរការកើនពីចំនួន ៤% ដល់ ៤១% សម្រាប់គ្រួសារទាំងអស់, កើនពីចំនួន 0% ដល់៣៣% សម្រាប់បញ្ហាភាគគ្រួសារក្រីក្របំផុត, កើនពីចំនួន ៤% ដល់ ៤០% សម្រាប់គ្រួសារដែលមានស្រ្តីជាមេគ្រួសារ និងកើនពីចំនួន ៤% ដល់ ៤២% សម្រាប់គ្រួសារដែលមានសមាជិកជាជនពិការ។

**ការពិនិត្យតាមដាន និងវាយតម្លៃ៖** មានការអង្កេតគ្រួសារ ៥ លើកក្នុងពេលអនុវត្តគម្រោងដើម្បីចងក្រងពីលទ្ធផលសម្រេចបាន។ កិច្ចពិភាក្សាក្រុមគោលដៅ ២ លើកត្រូវបានធ្វើឡើង ដើម្បីធ្វើការវាស់វែងបែបគុណភាពលើសូចនាករនិរន្តរភាពមុនពេលរៀបចំកម្មវិធី។ ទិន្នន័យពីការអង្កេតគ្រួសារត្រូវបានបែងចែកជាប្រភេទទៅតាមក្រុមងាយរងគ្រោះផ្សេងៗ ដែលកំណត់ដោយការស្រាវជ្រាវ បណ្តើរៗ។ ទិន្នន័យបែបបរិមាណត្រូវបានបម្លែងជាបរិមាណដើម្បីវាស់វែងសូចនាករ ដោយប្រើប្រព័ន្ធព័ត៌មានបែបគុណភាព (QIS) (ឧ. ការកំណត់ "ពិន្ទុ" សម្រាប់ការពិពណ៌នាការពិត និងខ្លឹស្តីពីស្ថានភាពមួយ)។ SNV បានសហការជាមួយអ្នកស្រាវជ្រាវមកពីសាកលវិទ្យាល័យ Emory ដើម្បីវិភាគទិន្នន័យ និងវាយតម្លៃលទ្ធផល។

**ការឆ្លុះបញ្ចាំង/មេរៀនសំខាន់ៗ៖**

- ការសិក្សា ដែលផ្តោតលើការកំណត់អត្តសញ្ញាណក្រុមងាយរងគ្រោះដោយសហការជាមួយរដ្ឋាភិបាលមូលដ្ឋាន និងសង្គមស៊ីវិល ជាគន្លឹះនៃការកំណត់គោលដៅសម្រាប់ការផ្តល់ជំនួយ និងមានការបែងចែកទិន្នន័យជាប្រភេទ

សម្រាប់តាមដានវឌ្ឍនភាព។

- សំខាន់បំផុតត្រូវមានភាពប្រាកប្រជា និងទទួលស្គាល់ថា ការដោះស្រាយបញ្ហាគុណវិបត្តិជាប្រព័ន្ធ ត្រូវចំណាយពេលយូរ និងមិនអាចលុបបំបាត់ឧបសគ្គមួយចំនួនក្នុងរយៈពេលខ្លីបានទេ។
- ការសម្រេចបានអនាម័យទូទាំងតំបន់ តម្រូវឱ្យមានកិច្ចខិតខំប្រឹងប្រែងយ៉ាងច្រើនលើក្រុមជួបការលំបាកធៀបនឹងក្រុមផ្សេងទៀត តាំងពីពេលចាប់ផ្ដើមកម្មវិធីដំបូង ។
- មានភាពតានតឹងរវាងការកែសម្រួលការគាំទ្រទៅតាមបរិបទមូលដ្ឋាន និងការរក្សាស្ដង់ដារនៃការគាំទ្រដើម្បីអាចពង្រីកវិសាលភាពដោយប្រសិទ្ធភាព។
- ការកំណត់អត្តសញ្ញាណក្រុមជួបការលំបាកអាចជាការលំបាក និងត្រូវការធនធានយ៉ាងច្រើន។
- តាមបណ្ដាស្រុកដែលមានកម្រិតអនាម័យទាប មានការលំបាកក្នុងការកំណត់ថាក្រុមណាមួយជួបការលំបាកបំផុត។ នៅពេលដែលកម្រិតអនាម័យក្នុងស្រុកមួយកើនឡើង ទើបគេអាចកំណត់ក្រុមដែលត្រូវការការគាំទ្រទៅតាមគោលដៅ។

ប្រភពព័ត៌មាន៖ ISF-UTS and SNV 2018; SNV 2017a; SNV 2017b; Reviewed by Anne Mutta (SNV)។

មេរៀនទូទៅ ៣ ក្នុងករណីសិក្សាទាំងនេះ រួមមាន ៖

- ការកំណត់អត្តសញ្ញាណក្រុមជួបការលំបាក និងការធានាថាពួកគេទទួលបានការគាំទ្រ ទាមទារនូវការវិនិយោគបន្ថែមលើការពិនិត្យតាមដាននិងវាយតម្លៃ ប៉ុន្តែផ្ដល់ផលគាប់ប្រសើរ។
- ការជំរុញការចូលរួមរបស់រដ្ឋាភិបាលមូលដ្ឋាន និងតួអង្គនៅមូលដ្ឋានផ្សេងទៀត ជាគន្លឹះក្នុងការអនុវត្ត និងបញ្ជ្រាបយន្តការគាំទ្រក្នុងស្ថាប័ន។
- ការគាំទ្រគួរត្រូវបានកែសម្រួលទៅតាមកម្រិត និងប្រភេទតម្រូវការ ៖ មិនមែនសហគមន៍ និងក្រុមជួបការលំបាកទាំងអស់ ត្រូវការការគាំទ្រក្នុងទំហំ ឬប្រភេទដូចគ្នានោះទេ។

## ករណីសិក្សាស្ដីពីការអនុវត្តយន្តការគាំទ្រ

ខណៈដែលវិស័យទឹកស្អាត និងអនាម័យបច្ចុប្បន្ន ផ្ដោតសំខាន់លើលទ្ធផលអនាម័យតាមរយៈយន្តការគាំទ្រ ការអនុវត្តយន្តការគាំទ្រត្រូវមានលក្ខណៈជាប្រព័ន្ធ ផ្អែកតាមភស្តុតាង និងមាននិរន្តរភាព។ ខាងក្រោមនេះជាជំហានដែលអ្នកអនុវត្តន៍អ្នកស្រាវជ្រាវ និងអ្នកតាក់តែងគោលនយោបាយអាចយកទៅអនុវត្តក្នុងរយៈពេលខ្លី ដើម្បីឈានទៅសម្រេចបាននិរន្តរភាព អនាម័យសម្រាប់មនុស្សគ្រប់រូបក្នុងទម្រង់ទាំងអស់នៃការរៀបចំកម្មវិធី និងការផ្ដល់សេវាអនាម័យ។ គួរពិចារណាពីចំណុចនីមួយៗដោយផ្អែកតាម "គោលការណ៍ធានាថា អ្នកដែលអាចជួបការលំបាក ទទួលបានអត្ថប្រយោជន៍ដោយប្រសិទ្ធភាពពីកម្មវិធី និងដំណើរការអនាម័យ" ដែលមានរៀបរាប់ក្នុងផ្នែកទី ១ នៃឯកសារនេះ។

- បង្កើតចំណុចដៅជាក់លាក់សម្រាប់កម្មវិធី និងការផ្ដល់សេវាដើម្បីសម្រេចបានស្ថានភាព គ្មានការបន្ទោរបង់ពាសវាលពាសកាលទូទាំងតំបន់ ដោយមានវឌ្ឍនភាពប្រកបដោយសមធម៌សម្រាប់ក្រុមទាំងអស់។
- ពិចារណាថាតើមានលក្ខខណ្ឌអំណោយផល សម្រាប់វិធីសាស្ត្រសហគមន៍ដឹកនាំអនាម័យទាំងស្រុងធម្មតា ឬថាតើត្រូវមានយន្តការគាំទ្របន្ថែមសម្រាប់ក្រុមជួបការលំបាក។
- សហការជាមួយអាជ្ញាធរមូលដ្ឋាន និងអ្នកតស៊ូមតិ និងតំណាងរបស់ក្រុមជួបលំបាក នៅគ្រប់ដំណាក់កាលទាំងអស់នៃអន្តរាគមន៍ដោយអនុវត្តគោលការណ៍ "ការគោរព និងមិនបង្កគ្រោះថ្នាក់"។
- បង្កើតសូនាករពិនិត្យតាមដាន និងវាយតម្លៃសំខាន់ៗ ឬវិធីសាស្ត្រសម្រាប់ធានាថា មនុស្សគ្រប់រូបអាចទទួលបាន និងប្រើប្រាស់បង្គន់អនាម័យ។
- រៀបចំថវិកា និងធ្វើផែនការសម្រាប់ការប្រមូលទិន្នន័យដែលបែងចែកជាប្រភេទដើម្បីពិនិត្យតាមដាន និងផ្ទៀងផ្ទាត់វឌ្ឍនភាពប្រកបដោយសមធម៌ឆ្ពោះទៅរក និងលើសពីស្ថានភាពគ្មានការបន្ទោរបង់ពាសវាលពាសកាល និងធ្វើផែនការស្ដីពីរបៀបប្រើប្រាស់ទិន្នន័យ។
- ជំរុញការចូលរួមរបស់រដ្ឋាភិបាលមូលដ្ឋាន និងតួអង្គតាមវិស័យផ្សេងទៀតក្នុងការរៀបចំ អនុវត្ត និងពិនិត្យតាមដានយន្តការគាំទ្រ ដោយរៀបចំផែនការច្បាស់លាស់ស្ដីពីរបៀបបញ្ជ្រាបយន្តការគាំទ្រក្នុងស្ថាប័នប្រកបដោយតម្លាភាព និងគណនេយ្យភាព។
- បង្កើតកម្រងយន្តការគាំទ្រដែលអាចអនុវត្តរួមគ្នា ដើម្បីបំពេញបន្ថែមឱ្យគ្នាទៅវិញទៅមក ជាពិសេសការរួមបញ្ចូលយន្តការហិរញ្ញវត្ថុជាមួយនឹងយន្តការគាំទ្រផ្សេងទៀត។
- ក្នុងការរៀបចំយន្តការគាំទ្រ ត្រូវគ្រប់គ្រងចំណាយលើកម្មវិធី និងភាពស្មុគស្មាញនៃការអនុវត្តយន្តការទាំងនេះ ដើម្បីឱ្យអាចបញ្ជ្រាបយន្តការទាំងនេះក្នុងស្ថាប័ន និងអាចពង្រីកបាន។
- រៀបចំយន្តការគាំទ្រ និងដំណើរការអនុវត្តន៍ ដែលសហគមន៍អាចយល់បាន

និងខិតខំជំរុញការចូលរួមរបស់ពួកគេ ក្នុងការធ្វើសេចក្តីសម្រេច ស្តីពីរបៀបអនុវត្តយន្តការទាំងនេះ និងអ្នកដែលគួរទទួលបានការគាំទ្រ។

- ពិចារណាពីជំហាននានាក្រៅពីស្ថានភាព គ្មានការបន្ទោរបង់ពាសវាលពាសកាល និងគិតពីរបៀបដែលក្រុមជួបការលំបាក អាចឈានទៅសម្រេចបានអនាម័យដែលគ្រប់គ្រងដោយសុវត្ថិភាព។
- បង្កើតភាពជាដៃគូរវាងអ្នកអនុវត្តន៍ និងអ្នកស្រាវជ្រាវ ដើម្បីបង្កើតភស្តុតាងសម្រាប់កំណត់ពីយន្តការដែលមានប្រសិទ្ធភាពក្នុងបរិបទជាក់លាក់។
- ចងក្រងលទ្ធផលរកឃើញស្តីពីភាពជោគជ័យ និងបញ្ហាប្រឈមដែលពាក់ព័ន្ធនឹងការគាំទ្រលទ្ធផលប្រកបដោយសមធម៌ រួមទាំងរបៀបរួម បញ្ចូលចំណេះដឹង និងបទពិសោធន៍របស់ក្រុមជួបការលំបាកបានល្អបំផុត និងចែករំលែកចំណុចទាំងនេះជាមួយវិស័យនេះ ដូចជា តាមរយៈគេហទំព័ររបស់ The Sanitation Learning Hub (https://sanitationlearninghub.org/)។

ក្រៅពីនេះ មានផ្នែកដែលតម្រូវឱ្យមានការស្រាវជ្រាវបន្ថែម ឬការពិចារណាជិតដល់ក្នុងវិស័យទឹកស្អាត និងអនាម័យ ដើម្បីផ្តល់មូលដ្ឋានព័ត៌មានដល់ជំហានបន្តបន្ទាប់ ស្តីពីការរៀបចំកម្មវិធីអនាម័យជនបទ និងការផ្តល់សេវាប្រកបដោយសមធម៌ ៖

- សូចនាករវាយតម្លៃទូទៅសម្រាប់វាស់វែងវឌ្ឍនភាព ប្រកបដោយសមធម៌ឆ្ពោះទៅសម្រេចបានចំណុចដៅទី ៦.២ នៃគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព។
- បែងចែកទិន្នន័យជាប្រភេទ ដើម្បីតាមដានវឌ្ឍនភាពនានា ឆ្ពោះទៅសម្រេចបានហេដ្ឋារចនាសម្ព័ន្ធអនាម័យប្រកបដោយនិរន្តរភាព។
- ភស្តុតាងបង្ហាញពីពេលវេលាសមស្របក្នុងការអនុវត្តយន្តការគាំទ្រ ធៀបនឹងការអនុវត្តអន្តរាគមន៍សហគមន៍ដឹកនាំអនាម័យទាំងស្រុងធម្មតា។
- ភស្តុតាងបង្ហាញពីកម្រងយន្តការគាំទ្រ ដែលមានប្រសិទ្ធភាពសម្រាប់ក្រុមជួបការលំបាកផ្សេងៗក្នុងបរិបទនានា។
- ភស្តុតាងបង្ហាញពីការកំណត់ពេលវេលាសមស្របដែលត្រូវអនុវត្តយន្តការគាំទ្រ ជាពិសេសការឧបត្ថម្ភថវិកា និងសម្ភារៈដល់អ្នកប្រើប្រាស់។
- យុទ្ធសាស្ត្រសម្រាប់ការផ្ទៀងផ្ទាត់ដោយប្រសិទ្ធភាព លើការប្រើប្រាស់បង្គន់ជាប់លាប់ ក្នុងចំណោមប្រជាជន រួមទាំងកន្លែងដែលមានការប្រើបង្គន់អនាម័យរួម។

**សង្ខេបចំណុចរៀនសូត្រសំខាន់ៗ៖**

- បទពិសោធន៍ជាក់ស្តែងបង្ហាញថា កម្មវិធីអនាម័យជនបទច្រើនតែមិនអាចចូលដល់ក្រុមជួបការលំបាកបំផុតឱ្យបានគ្រប់គ្រាន់។ យន្តការគាំទ្រអាចជួយធានាថា គ្មានបុគ្គលណាម្នាក់ត្រូវបានមើលរំលង។
- ការគាំទ្រដល់ក្រុមជួបការលំបាកមិនសុទ្ធតែត្រូវមានទម្រង់ជា "ផ្នែករឹង" ឬ "ផ្នែកទន់" នោះទេ ប៉ុន្តែត្រូវច្របាច់បញ្ចូលគ្នានូវការគាំទ្រទាំងពីរនេះឱ្យមានប្រសិទ្ធភាព។
- មិនសូវមានការចងក្រងឯកសារស្តីពីបទពិសោធន៍ និងភស្តុតាងលទ្ធផលសម្រាប់យន្តការគាំទ្រឡើយ ជាពិសេសក្នុងបរិបទអាហ្វ្រិក។ ការធ្វើផែនការ និងការបែងចែកថវិកាសម្រាប់ការពិនិត្យតាមដានលទ្ធផល និងផលប៉ះពាល់ និងការចែករំលែកមេរៀន ជាគន្លឹះក្នុងការពង្រឹងមូលដ្ឋានភស្តុតាងសម្រាប់ការរៀបចំការគាំទ្រដោយប្រសិទ្ធភាព។
- ការប្រើប្រាស់យន្តការគាំទ្រដោយជោគជ័យ មានន័យថា សម្រេចបានអនាម័យដែលបានកែលម្អ និងត្រូវបានប្រើប្រាស់ដោយមនុស្សគ្រប់រូបក្នុងតំបន់ទាំងមូល ការពង្រឹងបរិយាកាសអំណោយផល ភាពប្រសើរឡើងរបស់តំបន់មួយមិនរាំងស្ទះវឌ្ឍនភាពរបស់តំបន់ផ្សេងទៀត ឬបង្កឧបសគ្គដល់ទីផ្សារ ហើយយន្តការគាំទ្រអាចពង្រីកបាន។
- នៅពេលកំណត់អត្តសញ្ញាណក្រុមជួបការលំបាក ដើម្បីទទួលបានការគាំទ្រ ប្រការសំខាន់ត្រូវដេញដោលការសន្មត ស្តីពីអ្នកដែលត្រូវការប្រភេទការគាំទ្រណាមួយ និងផ្អែកលើភស្តុតាង។ ការកំណត់អត្តសញ្ញាណគួរធ្វើឡើងជាប្រចាំក្រោមការពិនិត្យតាមដាន និងការវាយតម្លៃដើម្បីធានាថា ក្រុមគោលដៅទទួលបានការគាំទ្រដែលពួកគេត្រូវការ។
- ត្រូវរក្សាតុល្យភាពរវាងភាពសាមញ្ញ តម្លាភាព និងភាពគ្រប់ជ្រុងជ្រោយនៅពេលកំណត់អត្តសញ្ញាណក្រុមនានាដែលត្រូវទទួលការគាំទ្រ អនុវត្តយន្តការគាំទ្រ និងពិនិត្យតាមដានគុណភាពនៃលទ្ធផល។
- "គ្មានពេលវេលាត្រឹមត្រូវឥតខ្ចោះមួយ" ក្នុងការអនុវត្តយន្តការគាំទ្រទេ ប៉ុន្តែវាអាស្រ័យលើលក្ខណៈរបស់យន្តការ និងបរិបទ។ សួរសំណួរត្រិះរិះស្តីពគុណសម្បត្តិ និងគុណវិបត្តិនៃការអនុវត្តយន្តការនៅពេលវេលាជាក់លាក់។
- ប្រើប្រាស់អស់លទ្ធភាពនូវទិន្នន័យដែលប្រមូលបាន និងបទពិសោធន៍ដែលបានចងក្រង តាមរយៈការរៀបចំដំណើរការដាក់បញ្ចូលទិន្នន័យ និងបទពិសោធន៍ទាំងនោះក្នុងការរៀបចំផែនការ អន្តរាគមន៍បន្តបន្ទាប់ និងការចែករំលែកមេរៀនជាមួយវិស័យទឹកស្អាត និងអនាម័យទាំងមូល។

# ឯកសារយោង

Bain, R. and Slaymaker, T. (2018) ' Progress in tracking Inequalities: Lessons from MDG Monitoring' in O. Cumming and T. Slaymaker (eds) *Equality in Water and Sanitation Services*, pp3-25, Oxon, UK: Routledge

Cavill, S., with Chambers, R. and Vernon, N. (2015) 'Sustainability and CLTS: Taking Stock', *Frontiers of CLTS: Innovations and Insights* Issue 4, Brighton: IDS, https://www.communityledtotalsanitation.org/sites/communityledtotalsanitation.org/files/Frontiers4_Sustainability_0.pdf (accessed 11 June 2019)

Cavill, S., Roose, S., Stephen, C. and Wilbur, J. (2016) 'Putting the Hardest to Reach at the Heart of the Sustainable Development Goals', in P. Bongartz, N. Vernon, and J. Fox (eds) *Sustainable Sanitation for All: Experiences, Challenges, and Innovations*, (245–266), Rugby, UK: Practical Action Publishing, https://www.developmentbookshelf.com/doi/pdf/10.3362/9781780449272.015 (accessed 11 June 2019)

Chambers, R. and Myers, J. (2016) 'Norms, Knowledge and Usage', *Frontiers of CLTS: Innovations and Insights* Issue 7, Brighton: IDS, https://www.communityledtotalsanitation.org/sites/communityledtotalsanitation.org/files/Frontiers_7_Norms_Knowledge_Usage.pdf (accessed 11 June 2019)

Coffey, D. and Spears, D. (2014) *How Can a Large Sample Survey Monitor Open Defecation in Rural India for the Swatch Bharat Abhiyan*, Working Draft, http://www.susana.org/_resources/documents/default/3-2176-7-1424791330.pdf (accessed 11 June 2019)

Crocker, J., Abodoo, E., Asamani, D., Domapielle, W., Gyapong, B. and Bartram, J. (2016) 'Impact Evaluation of Training Natural Leaders During a Community-Led Total Sanitation Intervention: a Cluster-Randomized Field Trial in Ghana', *Environmental Science & Technology*, 50.16: 8867-75

Cronin, A. A., Gnilo, M. E., Odagiri, M. and Wijesekera, S. (2017) 'Equity Implications for Sanitation from Recent Health and Nutrition Evidence', *International Journal for Equity in Health*, 16.1: 211

Cumming, O. and Curtis, V. (2018) 'Implications of WASH Benefits Trials for Water and Sanitation', *The Lancet Global Health*, 6.6: e613

Dwan, P., and Bond, M. (2016) *Evaluation Report: WaterSHED's Hands-Off Sanitation Marketing Program*, Australia: FH Designs

EMW (2016) *Community Hygiene Output-Based Aid (CHOBA): Project completion report*, Oakland: Thrive Networks

Gero, A. and Willetts, J. (2019, in press) 'Securing a Conducive Environment for Water, Sanitation and Hygiene Markets: The Role of Local Government', *Waterlines*

Grant, M., Murta, J., Willetts, J., Carrard, N. and Powell, B. (2016) *Civil Society Organisations' Learning for Impact in Water, Sanitation and Hygiene Programming: Report for the CS WASH Fund*, Sydney: UTS-ISF

House, S., Cavill, S. and Ferron, S. (2017) 'Equality and Non-Discrimination (EQND) in Sanitation Programmes at Scale (Part 1 of 2)', *Frontiers of CLTS: Innovations and Insights* Issue 10, Brighton: IDS, https://www.communityledtotalsanitation.org/sites/communityledtotalsanitation.org/files/Frontiers10_EQND.pdf (accessed 11 June 2019)

iDE. (n.d.) *iDE's Approach to Sanitation Marketing*, https://cdn-ms.ideglobal.org/www/documents/iDE-Sanitation-Marketing-Best-Practices.

pdf?mtime=20181228141047 (accessed 24 May 2019)

ISF-UTS (2016) *Driving Equality in Water and Sanitation Services Delivered by Enterprises: Guidance for Civil Society Organisations*, Sydney: ISF-UTS, http://enterpriseinwash.info/ (accessed 26 June 2019)

ISF-UTS and SNV (2018) *Sanitation for All: A Comparative Study of Approaches to Leaving No One Behind Across Five Countries*, The Hague: SNV, https://www.uts.edu.au/sites/default/files/article/downloads/SNV%20ISF_San4All_ACmprativStudy_2018%5B1%5D.pdf (accessed 26 June 2019)

Jenkins, M. and Pedi, D. (2013) *Guidance Note 8: Equity in Sanitation Marketing: How Can We Support the Market to Reach the Poorest?*, New York, USA

Kar, K. and Chambers, R. (2008) *Handbook on Community-Led Total Sanitation*, London and Brighton: Plan International and IDS, https://www.communityledtotalsanitation.org/sites/communityledtotalsanitation.org/files/media/cltshandbook.pdf (accessed 26 June 2019)

Larson, A. and Connell, J. (2015) *Verification of Sanitation Outcomes in Vietnam and Cambodia through the CHOBA Project: Final Report*, Social Dimensions, Geraldton, Australia

Murta, J., Foster, T. and Willetts, J. (2017) *Review of SNV's Pro-Poor Support Mechanism in Banteay Meas*, Cambodia, Sydney: ISF-UTS

Musembi, C.N. and Musyoki, S.M. (2016) 'CLTS and the Right to Sanitation', *Frontiers of CLTS: Innovations and Insights* Issue 8, Brighton: IDS, https://www.communityledtotalsanitation.org/sites/communityledtotalsanitation.org/files/Frontiers8_Human_Rights_red.pdf (accessed 11 June 2019)

Myers, J., Maule, L., Gnilo, M., Chambers, R. and Cavill, S. (2017) 'Supporting the Least Able Throughout and Beyond CLTS', *CLTS Knowledge Hub Learning Brief* 3, Brighton: IDS, https://www.communityledtotalsanitation.org/sites/communityledtotalsanitation.org/files/Supporting_the_least_able.pdf (accessed 11 June 2019)

Nguyen, H. H., Ljung, P. and Nguyen, M. C. (2013) *Targeting the Poor in Sanitation and Hygiene Programs Through Result-Based Financing in Vietnam*, Oakland: Thrive Networks

OHCHR (2012) *Human Rights Indicators: A Guide to Measurement and Implementation*, Geneva: OHCHR

Papafilippou, N., Templeton, M. and Ali, M. (2011) 'Is There a Role for External Technical Support in the Community-Led Total Sanitation (CLTS) Approach?', *International Development Planning Review*, 33.1: 81-94

Roaf, V., de Albuquerque, C. and Heller, L. (2018) 'The Human Rights to Water and Sanitation: Challenges and Implications for Future Priorities', in O. Cumming and T. Slaymaker (eds) *Equality in Water and Sanitation Services* (26–45) Oxon, UK: Routledge

Robinson, A. and Gnilo, M. (2016) 'Beyond ODF: a Phased Approach to Rural Sanitation Development', in P. Bongartz, N. Vernon, and J. Fox (eds) *Sustainable Sanitation for All: Experiences, Challenges, and Innovations* (155–166), Rugby: Practical Action Publishing Ltd, https://www.developmentbookshelf.com/doi/pdf/10.3362/9781780449272.009 (accessed 26 June 2019)

Sinha, A., Nagel, C. L., Thomas, E., Schmidt, W. P., Torondel, B., Boisson, S. and Clasen, T. F. (2016) 'Assessing latrine Use in Rural India: A Cross-Sectional Study Comparing Reported Use and Passive Latrine Use Monitors', *American Journal of Tropical Medicine and Hygiene*, 95.3: 720–727

SNV (2015) *Barriers and Facilitators to Hygienic Use and Maintenance of Latrines and Handwashing with Soap in Sarlahi, Mahottari, Siraha and Saptari Districts*

*of the Terai, Nepal*, Kathmandu: SNV

SNV (2017a) *Tanzania – SSH4A Results Programme Endline Brief*, The Hague: SNV

SNV (2017b) *Zambia – SSH4A Results Programme Endline Brief*, The Hague: SNV

UNICEF (2016) *Final narrative report – WASH Haiyan Recovery*, Manila: UNICEF

UNSD (2017) *Report of the Inter-Agency and Expert Group on Sustainable Development Goal Indicators*, UNSD: New York

Venkataramanan, V., Crocker, J., Karon, A. and Bartram, J. (2018) 'Community-Led Total Sanitation: A Systematic Review of Evidence and its Quality', *Environmental Health Perspectives*, 126.2: 26001

WASHPaLS (2018) *Research Project #2: CLTS + Subsidies Inception Report*, Washington D.C.: USAID

WaterAid, Plan International, and UNICEF (2018) *Guidance on Costing of Rural Sanitation Approaches*, London: WaterAid

WHO (2018) *Guidelines on Sanitation and Health*, Geneva: WHO

Wilbur, J., Gosling, L. and Jones, H. (2018) 'Breaking the barriers: disability, ageing and HIV in inclusive WASH programming', in O. Cumming and T. Slaymaker (eds) *Equality in Water and Sanitation Services*: 157–175, Oxon, UK: Routledge

Willetts, J. (2013) *Supporting the Poor to Access Sanitation in Bokeo Province, Laos*, Sydney: UTS-ISF, https://www.uts.edu.au/sites/default/files/article/downloads/willetts2013supportingpoorinsanitation.pdf (accessed 26 June 2019)

Willetts, J. and Powell, B. (2016) *Financing Sanitation: Finding a Middle Path to Reach the Poor*, Brisbane: CS WASH Fund, http://enterpriseinwash.info/wp-content/uploads/2019/01/Willetts-and-Powell_2016_LearningBrief_Financing-sanitation-to-reach-the-poor.pdf (accessed 26 June 2019)

## អំពីអ្នកនិពន្ធ

Jeremy Kohlitz ជាទីប្រឹក្សាស្រាវជ្រាវជាន់ខ្ពស់នៅសាកលវិទ្យាល័យបច្ចេកវិទ្យាស៊ីដនី (វិទ្យាស្ថានអនាគតប្រកបដោយនិរន្តរភាព) ដែលមានឯកទេសផ្នែកការស្រាវជ្រាវអន្តរវិស័យ និងអនុវត្តន៍ស្តីពីទឹកស្អាត និងអនាម័យ។

Naomi Carrad ជានាយកផ្នែកស្រាវជ្រាវនៃសាកលវិទ្យាល័យបច្ចេកវិទ្យាស៊ីដនី (វិទ្យាស្ថានអនាគតប្រកបដោយនិរន្តរភាព) ដែលមានឯកទេសផ្នែកការស្រាវជ្រាវអនុវត្តន៍សម្រាប់ផ្តល់មូលដ្ឋានព័ត៌មានដល់គោលនយោបាយ និងការអនុវត្តក្នុងវិស័យទឹកស្អាត និងអនាម័យ។

Juliet Willetts ជាសាស្ត្រាចារ្យនៃសាកលវិទ្យាល័យបច្ចេកវិទ្យាស៊ីដនី (វិទ្យាស្ថានអនាគតប្រកបដោយនិរន្តរភាព)។ លោកស្រីដឹកនាំការស្រាវជ្រាវអនុវត្តន៍ដើម្បីកែលម្អគោលនយោបាយអភិវឌ្ឍន៍ និងការអនុវត្ត និងលើកឡើងពីយុត្តិធម៌សង្គម និងការអភិវឌ្ឍប្រកបដោយនិរន្តរភាព រួមទាំង ការសម្រេចបានគោលនយោបាយអភិវឌ្ឍន៍ប្រកបដោយចីរភាព។

## អំពីកម្រងឯកសារនេះ

នេះជាកម្រងកំណត់សម្គាល់ខ្លីៗដែលផ្ដល់ការណែនាំជាក់ស្ដែងស្ដីពីមធ្យោបាយ
និងវិធីសាស្ត្រថ្មីៗ និងការពិចារណាពីបញ្ហាផ្សេងទៀត។
យើងខ្ញុំរីករាយនឹងទទួលយកមតិ គំនិត និងការលើកឡើងទាំងឡាយ។
សូមទាក់ទងមកយើងខ្ញុំតាមអាសយដ្ឋាន ៖ SLH@ids.ac.uk។

## កម្រងឯកសារផ្សេងទៀតដែលបានបោះពុម្ពផ្សាយ

កម្រងឯកសារទាំងអស់អាចរកបានតាមគេហទំព័រ ៖
www.https://sanitationlearninghub.org/series/frontiers-of-sanitation/

**ឯកសារទី ១ ៖** Cole, B. (2013) `Participatory design development for sanitation´

**ឯកសារទី ២ ៖** Maulit, J.A. (2014) `How to trigger for handwashing with soap´

**ឯកសារទី ៣ ៖** Wilbur, J and Jones, H. (2014) `Disability: Making SLH fully inclusive´

**ឯកសារទី ៤ ៖** Cavill, S. with Chambers, R. and Vernon, N. (2015) `Sustainability and SLH: Taking stock´

**ឯកសារទី ៥ ៖** House, S. and Cavill, S. (2015) `Making sanitation and hygiene safer: Reducing vulnerabilities to violence´

**ឯកសារទី ៦ ៖** Roose, S., Rankin, T. and Cavill, S. (2015) `Breaking the next taboo: Menstrual hygiene within SLH´

**ឯកសារទី ៧ ៖** Chambers, R. and Myers, J. (2016) `Norms, knowledge and usage´

**ឯកសារទី ៨ ៖** Musembi, C. and Musyoki, S. (2016) `SLH and the right to sanitation´

**ឯកសារទី ៩ ៖** Greaves, F. (2016) `SLH in post-emergency and fragile states settings´

**ឯកសារទី ១០ ៖** House, S., Cavill, S. and Ferron, S. (2017) `Equality and non-discrimination (EQND) in sanitation programmes at scale´

**ឯកសារទី ១១ ៖** Cavill, S., Mott, J. and Tyndale-Biscoe, P., with Bond, M., Huggett, C. and Wamera, E. (2018) `Engaging men and boys in sanitation and hygiene programmes´, Frontiers of SLH:Innovations and Insights 11, Brighton: IDS

**ឯកសារទី ១២ ៖** Myers, J. (ed) (2019 `Rural Sanitation in Africa: Challenges, Good Practices and Ways Forward´

# យន្តការគាំទ្រដើម្បីពង្រឹងសមភាព និងការមិនរើសអើង (EQND) ក្នុងអនាម័យនៅជនបទ ( ភាគ ២/២ )

ដើម្បីសម្រេចលទ្ធភាពទទួលបានអនាម័យគ្រប់គ្រាន់ និងប្រកបដោយសមធម៌សម្រាប់មនុស្សគ្រប់រូប និងការបញ្ឈប់ការបន្ទោរបង់ពាសវាលពាសកាលចាំបាច់ត្រូវផ្តោតការយកចិត្តទុកដាក់ជាពិសេសលើក្រុមជួបការលំបាក។ច្បាស់ណាស់ថាអត្ថប្រយោជន៍នៃការរៀបចំកម្មវិធីអនាម័យជនបទ និងការផ្តល់សេវាកន្លងមកច្រើនតែមានរបាយមិនស្មើគ្នា និងបង្កជាហានិភ័យនៃការមិនអើពើចំពោះក្រុមជួបការលំបាក។ កម្រងឯកសារ "ព្រំដែននៃកម្មវិធីសហគមន៍ ដឹកនាំអនាម័យទាំងស្រុង" ពិនិត្យមើលសក្តានុពលនៃការរៀបចំយន្តការគាំទ្រដើម្បីជួយឱ្យក្រុមជួបការលំបាក មានលទ្ធភាពនិងបានប្រើប្រាស់បង្គន់អនាម័យឆ្ពោះទៅរកការជំរុញ លទ្ធផលអនាម័យជនបទ ដែលកាន់តែមានសមធម៌។ កម្រងឯកសារនេះ លើកឡើងពីការពិចារណាថ្មីៗស្តីពីឱកាស និងបញ្ហាប្រឈមនៃយន្តការគាំទ្រ ព្រមទាំងស្វែងយល់ពី កិច្ចការដែលត្រូវធ្វើបន្តទៀត។



Illustration by Jamie Eke

វិទ្យាស្ថានសិក្សាអភិវឌ្ឍន៍ (IDS) នៃសាកលវិទ្យាល័យ Sussex, Brighton BN1 9RE
គេហទំព័រ ៖ https://sanitationlearninghub.org/
អ៊ីមែល ៖ SLH@ids.ac.uk
Twitter ៖ @SanitationLearningHub
ទូរស័ព្ទ ៖ +44 (0) 1273 606261
ទូរសារ ៖ +44 (0) 1273 621202

IDS ជាក្រុមហ៊ុនសប្បុរសធម៌ក្រោមការធានាមានកម្រិត ៖ Registered Charity No. 306371; Registered in England 877338; VAT No. GB 350 899914

## ស្វែងយល់បន្ថែមទៀត

ជាវ ព្រឹត្តិប័ត្រកម្មវិធីសហគមន៍ដឹកនាំអនាម័យទាំងស្រុង (SLH ចែករំលែកបទពិសោធន៍របស់អ្នក និងរួមចំណែកដល់គេហទំព័ររបស់ SLH តាមអ៊ីមែល ៖ SLH@ids.ac.uk